ISSN 1560-7615 / ISBN 978-99950-52-06-5

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

# ទស្សនាវដ្តី អភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី ១៩ លេខ ២ ខែមិថុនា ២០១៥ តម្លៃ ១.៥០០៛

# កសិកម្មឆ្លាតខាងអាកាសធាតុ៖ ប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវនៅកម្ពុជា

## សាវតា

វិស័យកសិកម្ម ដើរតួនាទីសំខាន់ក្នុងការទ្រទ្រង់ជីវភាពនៅជនបទកម្ពុជា ដោយមានប្រជាជនជនបទ ៨៣% ចូលរួមធ្វើសកម្មភាពកសិកម្ម (NIS and MAFF 2014)។ នៅចំពោះមុខផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ដែលបង្កឲ្យមានការផ្លាស់ប្តូរលំនាំទឹកភ្លៀង សីតុណ្ហភាពក្តៅជាងមុន ទឹកជំនន់និងការរាំងស្ងួតកើតមានញឹកញាប់ជាងមុន និង ជំងឺនិងសត្វចង្រៃកើតមានលើដំណាំកសិកម្មកាន់តែច្រើនជាងមុន (MOE and UNDP 2011) របៀបរបបធ្វើកសិកម្មឆ្លាតខាងអាកាសធាតុ កាន់តែមានសារៈសំខាន់ស្នូលនៅក្នុងការបន្សាំ និងពង្រឹងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ។ "កសិកម្មឆ្លាតខាងអាកាសធាតុ គឺជា កសិកម្មដែលមានចីរភាពក្នុងការជួយបង្កើនផលិតភាព និងភាពធន់ (ការបន្សាំ) ជួយកាត់បន្ថយ/បំបាត់ឧស្ម័នផ្ទះកញ្ចក់ និងពង្រីកជោគជ័យនៃគោលដៅពង្រឹងសន្តិសុខស្បៀងនិងអភិវឌ្ឍជាតិ" (FAO 2013, 2)។



កសិកររៀបចំដីរបស់ខ្លួន ដើម្បីធ្វើស្រូវវស្សា នៅខេត្តកំពង់ធំ ខែឧសភា ឆ្នាំ២០១៥។

ប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវ (SRI) ជារបៀបអនុវត្តឆ្លាតខាងអាកាសធាតុមួយ ដែលអង្គការ សេដាក (មជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មកម្ពុជា) បានណែនាំឲ្យស្គាល់នៅឆ្នាំ២០០០។តាំងពីពេលនោះមក ទីភ្នាក់ងាររដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាលផ្សេងៗ បានងាកទៅយកចិត្តទុកដាក់ជំរុញការប្រើប្រាស់ប្រព័ន្ធនេះនៅទូទាំងប្រទេស។ នៅខែមករា ២០០៥ មានការបង្កើត លេខាធិការដ្ឋាន SRI នៅក្រោម នាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដីកសិកម្ម ដែលក្រោយមកប្តូរឈ្មោះជាអគ្គលេខាធិការដ្ឋានកសិកម្ម (Ngin 2010)។

SRI ជា វិធីសាស្ត្របែបសរីរាង្គអតិពលកម្មប្រើទឹកតិច ដែលផ្អែកលើការស្ទូងដើមស្រូវឲ្យឃ្លាតពីគ្នាធំៗ។ វារួមបញ្ចូលនូវរបៀបអនុវត្តល្អៗបំផុតមួយសំណុំ ដែលអាចបង្កើនទិន្នផលស្រូវលើដីខ្សត់ជីជាតិ រហូតដល់ ១៥តោន/ហិកតា, ជួយកាត់បន្ថយបរិមាណទឹកត្រូវស្រោចស្រព, និងប្រើប្រាស់តែធាតុចូលក្នុងស្រុក (Stoop, Uphoff and Kassam 2002; Uphoff 2007; Kassam, Stoop and Uphoff 2011)។ ដើមឡើយ គេបានបង្កើតរបៀបអនុវត្ត SRI នេះឡើងសម្រាប់ជំរុញការដាំដុះត្រូវប្រើទឹកស្រោចស្រព ជាជាងដំណាំពឹងផ្អែកលើទឹកភ្លៀង។ វារួមមាន ការស្ទូងកូនសំណាបអាយុ ៨-១២ថ្ងៃ តែមួយដើម (ជំនួសឲ្យកូនសំណាបមួយកញ្ចំអាយុ ៣០-៣៥ថ្ងៃ) តាមលំនាំក្រឡាចតុរង្គ ២៥ x ២៥ សង់ទីម៉ែត្រ,

អត្ថបទនេះ រៀបចំដោយ សំ ស្រីមុំ អ្នកស្រាវជ្រាវ ផ្នែកបរិស្ថាន។ សូមយោងអត្ថបទនេះថា Sam Sreymom. 2015. "Climate-Smart Agriculture: System of Rice Intensification in Cambodia." *Cambodia Development Review* 19(2): 1-6. Phnom Penh: CDRI.

## មាតិកា

កសិកម្មឆ្លាតខាងអាកាសធាតុ៖ ប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវនៅកម្ពុជា ........ ១
ការចុះកិច្ចសន្យាផ្តល់សេវាសុខាភិបាលសាធារណៈ៖ ពីទស្សនៈ និងការយល់ដឹងស៊ីជម្រៅរបស់បុគ្គលិកសុខាភិបាល ........ ៧
តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស ........ ១២
— ស្ថានភាពក្នុងប្រទេស ........ ១៣
— សូចនាករ ........ ១៥
ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI ........ ២០

តារាង ១៖ តំបន់សិក្សា

| តំបន់កសិអេកូឡូស៊ី | ខេត្ត | ស្រុក | ឃុំ |
|---|---|---|---|
| ទន្លេសាប | កំពង់ឆ្នាំង | សាមគ្គីមានជ័យ | ធ្លកវៀន |
| | | ទឹកផុស | តាំងក្រសាំង |
| | កំពង់ធំ | ប្រាសាទបល្ល័ង្គ | សាលាវិស័យ |
| | | ស្ទឹងសែន | អូរគន្ធរ |
| មេគង្គក្រោម | ព្រៃវែង | កញ្ជៀច | ចុងអំពិល |
| | | បាភ្នំ | ជាយ |
| | តាកែវ | កោះអណ្តែត | ក្រពុំឈូក |
| | | ត្រាំកក់ | ត្រពាំងធំខាងជើង |

ការស្រោចស្រពយូរៗម្តង (ជាជាងការស្រោចស្រពមានទឹកត្រាំគល់ស្រូវជាប់រហូត), ការប្រើប្រាស់សារធាតុសរីរាង្គដែលរឹតតែប្រសើរបើសិនមានជីកំប៉ុស (ផ្ទុយស្រឡះពី ការពឹងផ្អែកលើធាតុចូលពីខាងក្រៅ) និងការជម្រះស្មៅជាទៀងទាត់។

ខុសពីការប្រើ បច្ចេកទេសក្សេត្រសាស្ត្រមួយសំណុំរឹងកំព្រឹសនោះ គោលការណ៍នៃ SRI មានលក្ខណៈអាចបត់បែន និងកែសម្រួលបានខ្លះ (Uphoff 2007)។ ទោះជារបៀបអនុវត្ត និងគោលការណ៍ស្នូល វានៅដដែលក្តី ប៉ុន្តែប្រព័ន្ធនេះបន្តវិវត្តទៅមុខដើម្បីសម្របតាមលក្ខខណ្ឌក្នុងមូលដ្ឋាន និងអាចឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។ របៀបអនុវត្ត SRI នាបច្ចុប្បន្ន ត្រូវបានកែសម្រួលសម្រាប់ការដាំដុះផ្អែកលើទឹកភ្លៀង (គ្មានការស្រោចស្រព) ហើយក្នុងនោះ ក៏មានការធ្វើស្រែតាមវិធីព្រោះគ្រាប់ស្រូវដោយផ្ទាល់ដែរ។

អត្ថបទនេះ ប្រើប្រាស់លទ្ធផលបានពីការសិក្សាធំទូលាយជាងនេះមួយ (Sam and Ouch 2015) ដើម្បីកំណត់ពីចំណេះដឹងក្នុងមូលដ្ឋាន និងការអនុវត្ត SRI នៅតំបន់កសិអេកូឡូស៊ីមេគង្គក្រោមនិងទន្លេសាប។អត្ថបទនេះពិនិត្យពីចន្លោះខ្វះខាតក្នុងរបៀបអនុវត្តនៅមូលដ្ឋាន ហើយស្នើឡើងនូវមធ្យោបាយសម្រាប់ភ្ជិតចន្លោះខ្វះខាតទាំងនោះ ដើម្បីជួយប្រជាជនឲ្យទប់ទល់នឹងឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ។

## វិធីសាស្ត្រ

ទិន្នន័យបឋម គេប្រមូលយកបានពី ការពិភាក្សាតាមក្រុមស្នូល (FGD) ចំនួន ៧, សម្ភាសន៍ស៊ីជម្រៅចំនួន ៨ និងសម្ភាសន៍អ្នកផ្តល់ព័ត៌មានគន្លឹះ (KII) ចំនួន ១១ ដែលធ្វើឡើងជាមួយនឹងអ្នកឆ្លើយតបនៅតាមតំបន់សិក្សា ក្នុងខេត្តកំពង់ឆ្នាំង កំពង់ធំ ព្រៃវែង និង តាកែវ (តារាង ១)។ ទិន្នន័យប្រភពទី២ រួមមាន ព័ត៌មានបែបគុណភាពស្តីពី របៀបអនុវត្ត SRI នៅតាមខេត្តគោលដៅ ដែលប្រមូលបានមកពីរបាយការណ៍របស់ស្ថាប័ននានា និងឯកសារផ្សេងៗទៀត។

KIIs បានអនុវត្តឡើងជាមួយតំណាងមកពី មន្ទីរកសិកម្មខេត្ត ការិយាល័យកសិកម្មស្រុក ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា[1] វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា, សេដាក និងគម្រោងពាក់ព័ន្ធនឹងអាកាសធាតុ ដូចជា HARVEST[2] និង PADEE[3]។ FGDs មានរួមបញ្ចូល មេឃុំ សមាជិកក្រុមប្រឹក្សាឃុំទទួលបន្ទុកលើកិច្ចការកសិកម្មក្នុងឃុំ និងប្រធានឬសមាជិកសហគមន៍កសិករប្រើប្រាស់ទឹកនៅមូលដ្ឋាន។

## លទ្ធផលរកឃើញសំខាន់ៗ

### *ការប្រើប្រាស់របៀបអនុវត្តន៍ SRI*

របៀបអនុវត្ត SRI មានប្រជាជនប្រើប្រាស់ច្រើនប៉ុណ្ណា វាប្រែប្រួលទៅតាមតំបន់កសិអេកូឡូស៊ី និងស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ច។ ម្យ៉ាងវិញទៀត ការដាក់អនុវត្តគោលការណ៍ SRI នៅក្នុងប្រព័ន្ធស្រោចស្រព និងប្រព័ន្ធពឹងផ្អែកលើទឹកភ្លៀង វាមិនខុសប្លែកពីគ្នាទេ ព្រោះកសិករមិនអាចគ្រប់គ្រងបរិមាណទឹកនៅលើដីស្រែរបស់ខ្លួន ដោយសារកង្វះប្រព័ន្ធដោះទឹក។ នៅតាមឃុំដែលក្រុមស្រាវជ្រាវបានធ្វើទស្សនកិច្ចនោះ របៀបអនុវត្ត និងគោលការណ៍ SRI មួយចំនួន មានការប្រើប្រាស់តែមួយភាគ ឬគ្មានសោះតែម្តង (តារាង ២)។ ចំណុចនេះ ឆ្លុះបញ្ចាំងជាសំខាន់ថា កសិករបានដាក់បញ្ចូល ឬកែសម្រួលរបៀបអនុវត្តន៍ទាំងនោះ ដើម្បីឲ្យស៊ីគ្នាល្អបំផុតទៅនឹង ស្ថានភាពជាក់លាក់របស់ខ្លួន។ ហេតុនេះ SRI មានការដាក់អនុវត្តខុសៗគ្នាទៅតាមតំបន់ផ្សេងៗគ្នា ឬសូម្បីក្នុងភូមិតែមួយក៏អាចមានការអនុវត្តខុសគ្នាដែរ។

*ការជ្រើសរើសប្រភេទស្រូវ៖* នៅតាមឃុំសិក្សា កសិករមានដាំស្រូវបីប្រភេទ៖ បែបទំនើប (IR 66, 504 និង 85), បែបប្រពៃណីមានការកែលំអ (រាំងជ័យ ផ្ការំដួល សូម៉ាលី និង ផ្ការម្ចិះ) និងបែបប្រពៃណី (ក្រញូល នាងយុន និង នាងទុំ)។ អ្នកចូលរួមក្នុង FGD និយាយថា កសិករចូលចិត្តដាំស្រូវប្រភេទទំនើបនៅដើមរដូវវស្សា និងនៅរដូវប្រាំង ព្រោះវាមានតម្លៃល្អនៅលើទីផ្សារ មានលក្ខណៈសមស្របនឹងស្ថានភាពដីនិងធាតុអាកាស មានចំណូលចិត្តពីអ្នកហូប មានទិន្នផលខ្ពស់ មានហានិភ័យតិចជាងប្រភេទ

1 កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា ផ្តល់អំណោយហិរញ្ញវត្ថុដល់អង្គការមិនមែនរដ្ឋាភិបាលនៅមូលដ្ឋានជាច្រើន ដើម្បីឲ្យធ្វើការលើផ្នែកការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។

2 គម្រោងជួយដោះស្រាយបញ្ហាភាពងាយរងគ្រោះនៅតំបន់ជនបទ និងស្ថិរភាពប្រព័ន្ធអេកូឡូស៊ី ទទួលបានមូលនិធិពី គំនិតផ្តួចផ្តើម United States Feed the Future និង United States Global Climate Change។

3 គម្រោងសម្រាប់ការអភិវឌ្ឍកសិកម្ម និងការផ្តល់សិទ្ធិអំណាចសេដ្ឋកិច្ច ទទួលបានជំនួយទ្រទ្រង់ពី មូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍកសិកម្ម និងផ្តោតលើ ការកែលំអជីវភាពប្រជាជនក្រីក្រ តាមការផ្តល់បច្ចេកវិទ្យាកសិកម្ម និងការបង្កើតក្រុមសន្សំប្រាក់នៅមូលដ្ឋាន។

ដទៃ និងធន់នឹងជំងឺ។ ជាពិសេសទៅទៀត ដើម្បីទប់ទល់នឹងការប្រែប្រួលអាកាសធាតុ កសិករបានផ្លាស់ប្តូរពីការប្រើប្រភេទស្រូវធ្ងន់និងផ្កាផ្លែតាមរដូវកំណត់ ទៅប្រើ ប្រភេទស្រូវស្រាលផ្កាផ្លែមិនតាមរដូវកំណត់។

*គ្រាប់ពូជ និងការរៀបចំសំណាប៖* កសិករភាគច្រើន បានបង្កើតវិធីសាស្ត្រផ្ទាល់ខ្លួន ដើម្បីរៀបចំគ្រាប់ពូជសម្រាប់ព្រោះ និងផលិតសំណាបសម្រាប់ស្ទូង។ កសិករខ្លះបានធ្វើបច្ចុប្បន្នភាពរបៀបអនុវត្តរបស់ខ្លួន នៅពេលគាត់បានយល់ដឹងប្រសើរឡើងពីបច្ចេកទេស និងបច្ចេកវិទ្យាដាំដុះ តាមការបណ្តុះបណ្តាលផ្តល់ឲ្យដោយ ការិយាល័យកសិកម្មស្រុក មន្ទីរកសិកម្មខេត្ត និងអង្គការមិនមែនរដ្ឋាភិបាលនានា។ ការរៀបចំគ្រាប់ពូជ តែងផ្សារភ្ជាប់ទៅនឹងស្ថានភាពក្នុងមូលដ្ឋាន។ កសិករមិនប្រើប្រាស់ទាំងស្រុងទេនូវបច្ចេកទេសបានពីការបណ្តុះបណ្តាល ប៉ុន្តែតែងគួបផ្សំរបៀបអនុវត្តខ្លះដែលខ្លួនបានរៀនសូត្រ ជាមួយនឹង របៀបអនុវត្តតាមធម្មតា និងចំណេះដឹងនៅក្នុងមូលដ្ឋាន។

*ការរៀបចំស្រែ៖* កសិកររៀបចំដីស្រែមុនពេលដាំដុះ ដោយការភ្ជួររាស់ និងកៀរផ្ទៃដីឲ្យស្មើ។ ការភ្ជួរ (ដោយកម្លាំងមនុស្ស ដោយប្រើសត្វអូសទាញ ឬដោយគ្រឿងយន្ត) តែងធ្វើឡើងពីរដង ឬ ៣ដង សម្រាប់ស្រែមានស្មៅដុះច្រើន។ ការកៀរផ្ទៃដី (ដោយកម្លាំងមនុស្ស ឬគ្រឿងយន្ត) ធ្វើឡើងតែម្តងប៉ុណ្ណោះ។ ក្នុងការអនុវត្តជាក់ស្តែង ប្រេកង់នៃសកម្មភាពទាំងនោះ វាផ្អែកទៅតាមបច្ចេកទេសភ្ជួរ វិធីដាំដុះ និងលទ្ធភាពចំណាយ។

*វិធីសាស្ត្រដាំដុះ៖* របៀបអនុវត្ត SRI តាមលំនាំដើម មិនមានការព្រោះស្រូវដោយផ្ទាល់ទេ ប៉ុន្តែការស្ទូងស្រូវគេឃើញមានអនុវត្តតែក្នុង ៤ឃុំ ប៉ុណ្ណោះ ក្នុងចំណោម ៨ឃុំ ដែលបានចុះសិក្សា។ អាយុសំណាបយកមកស្ទូង ប្រែប្រួលទៅតាមប្រភេទស្រូវ និងទឹកដែលមាន។ កសិករបានដឹងថា កូនសំណាបក្មេងឲ្យផលខ្ពស់ជាង ហើយតែងប្រឹងប្រើវានៅគ្រប់ពេលអាចធ្វើទៅបាន បើសិនមានទឹកគ្រប់គ្រាន់។ ការសម្រេចចិត្តធ្វើស្រូវស្ទូង ឬស្រូវពង្រោះ វាអាស្រ័យលើលក្ខខណ្ឌបរិស្ថាន និងរបៀបអនុវត្តក្នុងមូលដ្ឋាន។ សន្ទូងមាំមួនមានសុខភាពល្អ អាចលូតលាស់ប្រជែងជាមួយស្មៅចង្រៃ ហើយធន់នឹងការកាត់បំផ្លាញដោយសត្វចង្រៃ នៅក្នុងដំណាក់កាលដំបូងនៃការដាំដុះ។ នៅតំបន់ខ្លះកសិករធ្វើស្រូវពង្រោះ ព្រោះមិនអាច ឬក៏មិនចង់ចំណាយពេល

តារាង ២៖ ការប្រើប្រាស់ ឬការកែសម្រួលរបៀបអនុវត្តន៍ SRI នៅតាមខេត្ត និងឃុំ

| របៀបអនុវត្តន៍ | ព័ត៌មានលំអិត | កំពង់ឆ្នាំង | | កំពង់ធំ | | ព្រៃវែង | | តាកែវ | |
|---|---|---|---|---|---|---|---|---|---|
| | | ធ្លកវៀន | តាំងក្រសាំង | អូរគន្ធរ | សាលាវិស័យ | ចុងអំពិល | ធាយ | ក្រពុំឈូក | ត្រពាំងធំខាងជើង |
| ការជ្រើសរើសប្រភេទស្រូវ | ទិន្នផលខ្ពស់ | √ | × | × | √ | √ | √ | √ | √ |
| | ធន់នឹងសត្វចង្រៃ ការរាំងស្ងួត និងទឹកជំនន់ | Δ | Δ | Δ | Δ | Δ | Δ | Δ | Δ |
| | សមស្របនឹងប្រព័ន្ធអេកូឡូស៊ី | √ | √ | √ | √ | √ | √ | √ | √ |
| | មានតម្រូវការទីផ្សារ | √ | √ | √ | × | √ | √ | √ | √ |
| ការរៀបចំគ្រាប់ពូជ | ការរៀបចំគ្រាប់ពូជ | √ | √ | √ | √ | √ | √ | √ | √ |
| ការរៀបចំដីស្រែ | ការភ្ជួរ | √ | √ | Δ | √ | Δ | Δ | Δ | √ |
| | ការរាស់ | √ | √ | √ | √ | √ | √ | √ | √ |
| | ការកៀរដីឲ្យស្មើ | Δ | Δ | Δ | Δ | Δ | Δ | Δ | Δ |
| សំណាប | អាយុសំណាប | Δ | Δ | × | Δ | × | × | × | Δ |
| វិធីដាំ | ការព្រោះស្រូវដោយផ្ទាល់ | × | Δ | Δ | Δ | Δ | Δ | Δ | Δ |
| | ការស្ទូងស្រូវ | Δ | Δ | × | Δ | × | × | × | Δ |
| ការគ្រប់គ្រងជីជាតិដី | សារធាតុសរីរាង្គ | Δ | Δ | × | Δ | Δ | × | × | Δ |
| | ជីអសរីរាង្គ | Δ | Δ | Δ | Δ | Δ | Δ | Δ | × |
| ការគ្រប់គ្រងទឹក | ការស្តុកទឹក | × | × | × | Δ | Δ | Δ | × | × |
| | ជម្រៅទឹក | Δ | Δ | Δ | Δ | Δ | Δ | Δ | Δ |
| | ការស្រោចស្រពយូរៗម្តង | Δ | Δ | Δ | Δ | Δ | Δ | Δ | Δ |
| ការគ្រប់គ្រងស្មៅចង្រៃ | ការជម្រះស្មៅ | Δ | Δ | Δ | Δ | Δ | Δ | Δ | Δ |

សម្គាល់៖ √ = ប្រើប្រាស់ទាំងស្រុង/កែសម្រួល។ Δ = ប្រើប្រាស់ខ្លះ/កែសម្រួល។ x = គ្មានប្រើប្រាស់សោះ

ត្រួតពិនិត្យស្រែរបស់ខ្លួន។ សព្វថ្ងៃ ដោយសារកង្វះកម្លាំងពលកម្ម កសិករដទៃទៀតបានផ្លាស់ប្តូរទៅធ្វើស្រូវពង្រោះវិញ ទោះបីដឹងថា វាផ្តល់ទិន្នផលទាបជាងស្រូវស្ទូងក្តី។ កសិករខ្លះ បានប្រើប្រាស់របៀបអនុវត្ត SRI៖ ជ្រើសរើសយកសំណាបក្មេង រឹងមាំ ហើយដាំវាជាជួរឃ្លាតឆ្ងាយពីគ្នា ក្នុងដង់ស៊ីតេ ១-៣ ដើមក្នុង ១គុម្ព។ កសិករធ្វើស្រូវពង្រោះ ត្រូវប្រើអត្រាព្រោះគ្រាប់ស្រូវខុសគ្នាពីអត្រាមានណែនាំនៅក្នុង SRI ដោយផ្អែកតាមប្រភេទស្រូវ និងទីកន្លែង។ នៅខេត្តតាកែវ ព្រៃវែង និង កំពង់ធំ កសិករអ្នកដាំស្រូវ IR504 តែងធ្វើការសាកល្បងក្នុងស្រែរបស់ខ្លួនផ្ទាល់ ដើម្បីគណនាបរិមាណគ្រាប់ពូជត្រូវប្រើ។

*ការគ្រប់គ្រងជីជាតិដី៖* សារធាតុសរីរាង្គអាចរក្សាទិន្នផលខ្ពស់ កែលំអទ្រង់ទ្រាយដី និងបង្កើនលទ្ធភាពផ្ទុកទឹកនិងជីវជាតិ។ ជីកំប៉ុសឃើញមានប្រើនៅក្នុង ៥ឃុំ រីឯកសិករនៅឃុំ អូរគន្ធរ ជាយ និងក្រពុំឈូក គិតថា គាត់ត្រូវចំណាយពេលយូរពេកទើបបានផលហើយពិបាកដឹកជញ្ជូនទៅកាន់ស្រែគាត់ដែលនៅឆ្ងាយ និងរាយប៉ាយដាច់ពីគ្នា។ អត្រាប្រើជីកំប៉ុសដែលគេណែនាំឲ្យប្រើ វាប្រែប្រួលទៅតាមប្រភេទដី។ ក្នុងការអនុវត្តជាក់ស្តែង កសិករប្រើជីក្នុងកម្រិតទាបជាងការណែនាំ ព្រោះគាត់អាចផលិត ឬដឹកជញ្ជូនបានតែប៉ុណ្ណោះ។ ប្រសិនបើ សារធាតុសរីរាង្គមិនមានគ្រប់គ្រាន់ ឬមួយដីស្រែនៅឆ្ងាយពេក កសិករអាចប្រើជីគីមីវិញ។ ក្រោយបានទទួលការបណ្តុះបណ្តាលជាច្រើនមក កសិករខ្លះបានយល់ដឹងពីជីប្រភេទខុសៗគ្នា ជីណាគួរប្រើ គួរប្រើច្រើនប៉ុណ្ណា នៅពេលណា និងលើដីប្រភេទណា។ កសិករខ្លះទៀតប្រើជីច្រើនលើសកម្រិតដោយគិតថា នឹងបានទិន្នផលខ្ពស់ ព្រោះគាត់មិនដឹងច្បាស់ថាត្រូវប្រើប៉ុន្មាននោះទេ។

*ការគ្រប់គ្រងទឹក៖* សូម្បីស្រែស្រោចស្រពដែលប្រើធាតុចូលកម្រិតទាប ក៏ឲ្យផលច្រើនជាងស្រែពឹងផ្អែកលើទឹកភ្លៀងដែរ។ គោលការណ៍សំខាន់បំផុតមួយនៃ SRI គឺការរក្សាដីឲ្យមានសំណើម តាមការស្រោចស្រពយូរៗម្តង ជាជាងការស្រោចស្រពឲ្យផ្អែតទឹករហូត។ ជម្រៅទឹក និងរបបស្រោចស្រព (ប្រេកង់ និងរយៈពេលមានទឹកលិច) ត្រូវកំណត់ច្បាស់សម្រាប់ដំណាក់កាលនីមួយៗនៃការលូតលាស់ស្រូវ ហើយផ្ទៃដីស្រែត្រូវតែស្មើគ្នាទាំងស្រុង ដើម្បីឲ្យបច្ចេកទេសប្រើទឹកកម្រិតទាបនេះ មានប្រសិទ្ធភាពខ្ពស់។ ឆ្លងតាមការបណ្តុះបណ្តាលផ្តល់ឲ្យដោយមន្ទីរកសិកម្មខេត្ត និងអង្គការមិនមែនរដ្ឋាភិបាល កសិករមានការយល់ដឹងល្អពី ជម្រៅទឹកចាំបាច់សម្រាប់ការលូតលាស់របស់ស្រូវ។ នៅតំបន់ពឹងផ្អែកលើទឹកភ្លៀង កសិករខ្លះហាក់អនុវត្តការស្រោចស្រពតាម SRI បានល្អ រីឯកសិករខ្លះទៀតដែលមិនមានស្រះ ទំនប់ ឬអូរ សម្រាប់ស្តុកទឹក ឬដោះទឹកភ្លៀងដែលមានច្រើនហួសពេក គាត់ពិបាករក្សាជម្រៅទឹកក្នុងស្រែ ឲ្យបានតាមការតម្រូវនៅក្នុង SRI។ នៅតាមតំបន់ស្រោចស្រពដែលកសិករតែងដោះទឹកតាមរយៈដីស្រែជាប់ៗគ្នានោះ ការរក្សាជម្រៅទឹករាក់ ក៏អាចជួបបញ្ហាដែរ ប្រសិនបើមិនមានប្រព័ន្ធដោះទឹក។ នៅតំបន់ដែលត្រូវបង់ថ្លៃទឹកស្រោចស្រព កសិករកម្រឲ្យមានទឹកហូរចេញពីស្រែរបស់គាត់ណាស់។ កសិករនៅក្នុងឃុំសិក្សាបានប្រាប់ថា ស្រែភាគច្រើនមិនមានផ្ទៃដីរាបស្មើល្អទេ ព្រោះគាត់មិនមានលទ្ធភាពប្រើគ្រឿងយន្ត កៀរផ្ទៃដីឲ្យស្មើ។

*ការគ្រប់គ្រងស្មៅចង្រៃ៖* កាលណាដីស្រែមិនមានទឹកលិចជាប់រហូតនោះជារឿយៗស្មៅចង្រៃតែងដុះលឿន។ការរក្សាគម្លាតទូលាយរវាងជួរដាំដុះ អាចជួយឲ្យដំណាំលូតលាស់លឿនជាងស្មៅចង្រៃក្នុងដំណាក់កាលដំបូងនៃការលូតលាស់។ ការជម្រះស្មៅចង្រៃ ភាគច្រើនធ្វើឡើងដោយដៃ ប៉ុន្តែមានកសិករខ្លះប្រើថ្នាំសម្លាប់ស្មៅ។ កសិករតែងដឹងពីពេលវេលាត្រូវចាប់ផ្តើមជម្រះស្មៅ និងវិធីទប់ស្កាត់ស្មៅប្រភេទជាក់លាក់ខ្លះកុំឲ្យវាដុះបាន។

## កត្តាជះឥទ្ធិពលលើការប្រើប្រាស់ SRI

សម្ភាសន៍ និងការពិភាក្សាតាមក្រុមស្នូល បានកំណត់កត្តាជាច្រើនដែលជះឥទ្ធិពលលើការទទួលយក SRI ដោយកសិករ ដូចមានសង្ខេបនៅក្នុង តារាង ៣ ហើយឥទ្ធិពលរបស់វាទៅលើការទទួលអនុវត្តន៍ SRI នីមួយៗ មានសង្ខេបនៅក្នុង តារាង ៤។ ទិដ្ឋភាពផ្សេងៗដែលទាក់ទាញកសិករឲ្យប្រើប្រាស់របៀបអនុវត្តន៍ SRI រួមមាន៖

- តម្រូវការកម្លាំងពលកម្មតិចជាងមុន សម្រាប់ការស្ទូង ព្រោះស្រូវ និងជម្រះស្មៅចង្រៃ
- លក្ខណៈសមស្របសម្រាប់ប្រព័ន្ធដាំដុះតូចៗ
- លទ្ធផលវិជ្ជមាន
- ផ្នត់គំនិតវិជ្ជមាន
- មានទឹកគ្រប់គ្រាន់
- មានធាតុចូល៖ គ្រាប់ពូជសុទ្ធ សារធាតុសរីរាង្គ ជី និងគ្រឿងយន្ត
- លទ្ធភាពផ្អែកទីផ្សារ ព័ត៌មានបច្ចេកទេស និងស្ថាប័ននៅជនបទ
- ហានិភ័យទាបជាងមុន
- ទិន្នផលខ្ពស់
- ដង់ស៊ីតេស្មៅចង្រៃទាបជាងមុន។

កត្តាបង្អាក់ទឹកចិត្តកសិករក្នុងការប្រើប្រាស់ SRI រួមមាន៖

- តម្រូវការកម្លាំងពលកម្មសម្រាប់ការស្ទូង ការកៀរផ្ទៃដីឲ្យស្មើ ការជម្រះស្មៅចង្រៃ និងការត្រួតពិនិត្យជម្រៅទឹក
- ភាពមិនសមស្របសម្រាប់ក្បាលដីច្រើនកន្លែង ឬធំៗ
- ទម្លាប់ និងផ្នត់គំនិតបែបបុរាណ
- ទឹកមិនគ្រប់គ្រាន់
- កង្វះធាតុចូលផ្អែកផលិតកម្ម
- លទ្ធភាពតូចដើម្បីបានប្រើប្រាស់ទីផ្សារ ព័ត៌មានបច្ចេកទេស និងស្ថាប័ននៅជនបទ
- ហានិភ័យពាក់ព័ន្ធនឹង អត្រាទាបនៃការព្រោះស្រូវ/ដង់ស៊ីតេសន្ទូង និងដង់ស៊ីតេខ្ពស់នៃស្មៅចង្រៃ។

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

SRI ជាវិធីមួយសម្រាប់បង្កើនផលិតភាពស្រូវ តាមរយៈការកែលំអការគ្រប់គ្រងដី ទឹក ជីជាតិ និងស្មៅចង្រៃ។ លទ្ធផលសិក្សាបង្ហាញថា នៅពេលកសិករបានសម្រេចចិត្តធ្វើបច្ចុប្បន្នភាព

តារាង ៣៖ កត្តាជំរុញ និងបង្អាក់ការប្រើប្រាស់ SRI លំអិតតាមឃុំ

| ឃុំ | តម្រូវការពលកម្ម | ដី (ចំនួនក្បាលដី ទំហំ និងចម្ងាយ) | ផ្នត់គំនិត និងទម្លាប់អនុវត្តន៍ក្នុងមូលដ្ឋាន | លទ្ធភាពទទួលបានទឹកប្រើប្រាស់ | លទ្ធភាពទទួលបានធាតុចូល | លទ្ធភាពផ្នែកទីផ្សារ | លទ្ធភាពទទួលបានព័ត៌មាន | ស្ថាប័នជនបទ | ហានិភ័យ | ទិន្នផល | ស្មៅចង្រៃ |
|---|---|---|---|---|---|---|---|---|---|---|---|
| ធ្លកវៀន | -/+ | - | - | - | | -/+ | + | -/+ | + | + | + |
| តាំងក្រសាំង | - | | - | -/+ | -/+ | | -/+ | | - | + | |
| អូរគន្ធរ | | - | -/+ | -/+ | -/+ | + | -/+ | + | + | - | + |
| សាលាវិស័យ | - | - | | -/+ | -/+ | + | -/+ | | | + | + |
| ចុងអំពិល | - | | - | - | -/+ | -/+ | -/+ | + | | - | |
| ធាយ | - | | | -/+ | + | + | + | + | + | + | |
| ត្រពុំឈូក | - | - | | -/+ | -/+ | -/+ | -/+ | + | | - | |
| ត្រពាំងធំខាងជើង | -/+ | - | + | -/+ | -/+ | | - | + | | + | |

សំគាល់៖ (-)កត្តាបង្អាក់ទឹកចិត្ត; (+) កត្តាជំរុញ

តារាង ៤៖ កត្តាជំរុញ និងបង្អាក់ទឹកចិត្តក្នុងការប្រើប្រាស់របៀបអនុវត្តន៍នីមួយៗនៃ SRI

| របៀបអនុវត្តន៍ | ព័ត៌មានលំអិត | តម្រូវការពលកម្ម | ដី (ចំនួនក្បាលដី ទំហំ និងចម្ងាយ) | ផ្នត់គំនិត និងទម្លាប់អនុវត្តន៍ក្នុងមូលដ្ឋានន | លទ្ធភាពទទួលបានទឹកប្រើប្រាស់ | លទ្ធភាពទទួលបានធាតុចូល | លទ្ធភាពផ្នែកទីផ្សារ | លទ្ធភាពទទួលបានព័ត៌មាន | ស្ថាប័នជនបទ | ហានិភ័យ | ទិន្នផល | ស្មៅចង្រៃ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ការជ្រើសរើសប្រភេទស្រូវ | ទិន្នផលខ្ពស់ | | | | -/+ | -/+ | -/+ | -/+ | -/+ | | -/+ | |
| | ធន់នឹងសត្វចង្រៃ ការរាំងស្ងួត និងទឹកជំនន់ | | + | + | -/+ | -/+ | -/+ | -/+ | -/+ | + | | + |
| | សមស្របនឹងប្រព័ន្ធអេកូឡូស៊ី | | + | -/+ | | | | -/+ | -/+ | + | | |
| | មានតម្រូវការទីផ្សារ | | -/+ | | + | -/+ | + | -/+ | -/+ | | | |
| ការរៀបចំគ្រាប់ពូជ | ការរៀបចំគ្រាប់ពូជ | | -/+ | + | -/+ | | + | + | | + | + | |
| | ការរៀបចំថ្នាល | | -/+ | -/+ | -/+ | | + | -/+ | | | + | |
| ការរៀបចំដីស្រែ | ការភ្ជួរដី | | -/+ | | | -/+ | + | | -/+ | | + | + |
| | ការរាស់ដី | | | | | -/+ | + | | | | + | |
| | ការកៀរផ្ទៃដីឲ្យស្មើ | -/+ | -/+ | | | -/+ | + | -/+ | | | + | + |
| សំណាប | អាយុសំណាប | | | -/+ | -/+ | | + | -/+ | | - | + | |
| | ការរៀបចំដីស្រែ | | -/+ | -/+ | -/+ | | + | -/+ | | | + | |
| វិធីដាំ | ការព្រោះគ្រាប់ស្រូវ | + | + | -/+ | -/+ | + | + | + | | | + | - |
| | ការស្ទូង | -/+ | -/+ | -/+ | -/+ | | + | -/+ | + | | + | + |
| ការកែលំអដី | សារធាតុសរីរាង្គ | - | -/+ | -/+ | -/+ | -/+ | + | -/+ | + | + | + | |
| | ជីអសរីរាង្គ | | -/+ | - | -/+ | -/+ | + | -/+ | + | | + | |
| ការគ្រប់គ្រងទឹក | ការស្តុកទឹក | | -/+ | | -/+ | | + | -/+ | -/+ | + | + | |
| | ជម្រៅទឹក | - | | - | -/+ | | + | -/+ | | -/+ | + | |
| | ការស្រោចស្រពយូរៗម្តង | - | | - | -/+ | | + | -/+ | | -/+ | + | |
| ការគ្រប់គ្រងស្មៅចង្រៃ | ការជម្រះស្មៅចង្រៃ | -/+ | -/+ | -/+ | -/+ | -/+ | + | -/+ | -/+ | -/+ | + | -/+ |

សំគាល់៖ (-) កត្តាបង្អាក់ទឹកចិត្ត (+) កត្តាជំរុញ

ផលិតកម្មរបស់ខ្លួនហើយនោះ គាត់មិនត្រឹមទទួលយករបៀបអនុវត្តន៍ SRI នោះទេ ប៉ុន្តែថែមទាំងមានកែសម្រួលវាខ្លះ ដើម្បីឲ្យស៊ីគ្នានឹងស្ថានភាពក្នុងមូលដ្ឋាន។ ទោះយ៉ាងណាក្តី កសិករជ្រើសយកតែរបៀបអនុវត្តន៍ណា ដែលគាត់គិតថា អាចធ្វើកើត និងមានប្រយោជន៍។ អាចធ្វើកើត មានន័យថា ងាយអនុវត្ត និងសមស្របតាមស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ច និងកសិអេកូឡូស៊ីក្នុងមូលដ្ឋាន។ របៀបអនុវត្តនេះមានប្រសិទ្ធភាពល្អនៅជនបទកម្ពុជាក្នុងកាលៈទេសៈបច្ចុប្បន្នដែលមានលទ្ធភាពតិចក្នុងការទទួលបានធាតុចូលដ៏ចាំបាច់ៗសម្រាប់ការដាំដុះ ក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ។

កត្តាចម្បងៗដែលជំរុញឲ្យកសិករប្រើប្រាស់ របៀបអនុវត្តន៍ SRI រួមមាន ទិន្នផលបានកាន់តែខ្ពស់ និងលទ្ធភាពផ្នែកទីផ្សារប្រសើរជាងមុន។ផ្ទុយមកវិញតម្រូវការកម្លាំងពលកម្មនិងលក្ខណៈដីធ្លី (ចំនួនក្បាលដី ទំហំ និងចម្ងាយ) ជារឿយៗអាចជាកត្តាបន្ទចបង្អាក់កសិករក្នុងការពិចារណាប្រើប្រាស់ SRI។ កត្តាផ្សេងៗទៀតក៏អាចជាកត្តាជំរុញ ឬក៏បង្អាក់ការប្រើប្រាស់ SRI ដែរ។

របៀបអនុវត្តន៍ SRI ក្នុងការជ្រើសរើសប្រភេទស្រូវ (លើកលែងប្រភេទស្រូវធន់នឹងសត្វចង្រៃ/ការរាំងស្ងួត/ទឹកជំនន់) ការរៀបចំគ្រាប់ពូជ និងការរាស់ដី (ការរៀបចំដីស្រែ) ហាក់ត្រូវបានអនុវត្តតាមទាំងស្រុង រីឯរបៀបជ្រើសរើសកូនសំណាប ដាំដុះ ភ្ជួរ និងកៀរផ្ទៃដីឲ្យស្មើ កែលំអដី គ្រប់គ្រងទឹក និងគ្រប់គ្រងស្មៅចង្រៃ គឺមានការអនុវត្តតាមតែខ្លះៗប៉ុណ្ណោះ។

ការកែលំអរបៀបអនុវត្ត SRI នៅកម្ពុជា ត្រូវប្រឹងប្រែងធ្វើជាបន្ទាន់ ដើម្បីភ្ជិតគម្លាតរវាងរបៀបអនុវត្តន៍ល្អវិសេសឬបានស្នើឡើង ជាមួយនឹង ការអនុវត្តជាក់ស្តែង និងដើម្បីដោះស្រាយបញ្ហានានាដែលរួមចំណែកបង្កើតគម្លាតទាំងនោះ។ កិច្ចប្រឹងប្រែងក្នុងទូទាំងប្រទេសត្រូវតែយកចិត្តទុកដាក់ជាប់រហូតមែនហើយ ប៉ុន្តែកិច្ចប្រឹងប្រែងក្នុងមូលដ្ឋាន ដែលមិនពឹងផ្អែកលើជំនួយទ្រទ្រង់ពីខាងក្រៅ ក៏សំខាន់ណាស់ដែរ ក្នុងការជួយកសិករទប់ទល់នឹងឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ។ សហគមន៍មូលដ្ឋានក៏ត្រូវកេណ្ឌប្រមូលធនធានក្នុងតំបន់ដែរ ដោយត្រូវធ្វើសកម្មភាពរួមគ្នាដើម្បីចែករំលែកព័ត៌មានបច្ចេកទេស កែសម្រួលរបៀបអនុវត្តន៍ដែលបានជ្រើសប្រើ ជួយសម្រួលលទ្ធភាពផ្នែកទីផ្សារនិងធាតុចូល កំណត់រកជម្រើសស្តុកទឹកនៅក្នុងមូលដ្ឋាន និងចែករំលែកហានិភ័យ និងកម្លាំងពលកម្ម។

អង្គការមិនមែនរដ្ឋាភិបាលនានា គួរសហការឲ្យកាន់តែជិតស្និទ្ធជាមួយ មន្ទីរក្រសួងជាប់ពាក់ព័ន្ធនឹងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និង SRI ដើម្បីពង្រីកដែនគ្របដណ្តប់នៃកសិកម្មឆ្លាតខាងអាកាសធាតុ។ ពួកគេក៏គួរ ផ្តោតការយកចិត្តទុកដាក់បន្ថែមលើការអនុវត្តបែបថ្មីនៅក្នុងមូលដ្ឋាន គិតគូរពីការតម្រូវផ្សេងៗផ្នែកបច្ចេកទេសដ៏ស្មុគស្មាញនៃ SRI និងពិនិត្យពីលទ្ធភាពកែសម្រួលលើរបៀបអនុវត្តន៍មួយៗផងដែរ។ លើសពីនេះទៀត អង្គការមិនមែនរដ្ឋាភិបាល និងរដ្ឋាភិបាល គួរផ្តល់សេចក្តីណែនាំផ្នែកទីផ្សារ តាមរយៈភ្នាក់ងារផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ដើម្បីជួយកសិករក្នុងការតភ្ជាប់ទៅនឹងទីផ្សារ។ បណ្តាស្ថាប័ន និងអ្នកឯកទេសទាក់ទងនឹង SRI ត្រូវចូលរួមផងដែរក្នុងកិច្ចការស្រាវជ្រាវនិងអភិវឌ្ឍន៍។ រដ្ឋាភិបាលគួរបង្កើនចំនួនភ្នាក់ងារធ្វើការតាមភូមិ និងប្រមែប្រមូលប្រជាជនមូលដ្ឋានឲ្យធ្វើការរួមគ្នា ក្នុងការផ្តល់សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម។

## ឯកសារយោង


FAO (Food and Agriculture Organization). 2013. *Facing the Challenges of Climate Change and Food Security: The Role of Research Extension and Communication for Development*. Accessed Jul 2015, www.fao.org/docrep/018/i3334e/i3334e.pdf.

Kassam, Amir, Willem Stoop and Norman Uphoff. 2011. “Review of SRI Modifications in Rice Crop and Water Management and Research Issues for Making Further improvements in Agricultural and Water Productivity.” *Paddy and Water Environment* 9(1): 163-180.

MOE and UNDP (Ministry of Environment and United Nations Development Programme). 2011. *Cambodia Human Development Report 2011*. Phnom Penh: UNDP.

Ngin Chhay. 2010. “Overview of SRI Application and Adoption in Cambodia.” Presentation at workshop on Consolidation of SRI Experiences, Lessons and Networking, Hanoi, Vietnam, 21-22 June.

NIS and MAFF (National Institute of Statistics and Ministry of Agriculture, Forestry and Fisheries). 2014. “Census of Agriculture in Cambodia 2013: Preliminary Report.” Phnom Penh: NIS and MAFF.

Sam Sreymom with Ouch Chhuong. 2015. *Agricultural Technological Practices for Climate Change Adaptation*. Working Paper Series No. 100. Phnom Penh: CDRI.

Stoop, Willem A., Norman Uphoff and Amir Kassam. 2002. “A Review of Agricultural Research Issues Raised by the System of Rice Intensification (SRI) from Madagascar: Opportunities for Improving Farming Systems for Resource-Poor Farmers.” *Agricultural Systems* 71(3): 249-274.

Uphoff, Norman. 2007. “Farmer Innovations Improving the System of Rice Intensification (SRI).” *Journal of Pure and Applied Microbiology* 9(2): 57-62. Accessed 12 Jul 2014. www.future-agricultures.org/farmerfirst/files/T1a_Uphoff.pdf.

# ការចុះកិច្ចសន្យាផ្តល់សេវាសុខាភិបាលសាធារណៈ៖ ពីទស្សនៈ និងការយល់ដឹងស៊ីជម្រៅរបស់បុគ្គលិកសុខាភិបាល

## សាវតា

ការកសាងប្រព័ន្ធសុខាភិបាលកម្ពុជាឡើងវិញ ក្នុង ២០ឆ្នាំកន្លងទៅនេះ ជាកិច្ចប្រឹងប្រែងដ៏អស្ចារ្យ ព្រោះត្រូវចាប់ផ្តើមសឹងតែពីបាតដៃទទេ ដោយមានហេដ្ឋារចនាសម្ព័ន្ធរងការខូចខាតយ៉ាងដំណំ និងវេជ្ជបណ្ឌិតមានការបណ្តុះបណ្តាលមិនដល់ ៥០នាក់ផងទេ (Ovesen and Trankell 2010)។ ក្រោមការជួយគាំទ្រវិនិយោគដ៏សំខាន់ពីរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា ក្នុងឆ្នាំ ១៩៨៩-១៩៩៥ការអនុវត្តកំណែទម្រង់វិស័យសុខាភិបាល (HSR) ដំណាក់កាលដំបូងបានចាប់ដំណើរការក្នុងឆ្នាំ១៩៩១-៩៤។ កំណែទម្រង់វិស័យសុខាភិបាលដំណាក់កាលទី២ បានចាប់ផ្តើមជាបន្តក្នុងឆ្នាំ១៩៩៥-៩៨។ ក្នុងដំណាក់កាលទី២នៃ កំណែទម្រង់នោះ ផែនការដែនគ្របដណ្តប់ផ្នែកសុខាភិបាល និងបទបញ្ញត្តិស្តីពីហិរញ្ញប្បទានផ្នែកសុខាភិបាលត្រូវបានបង្កើតឡើង ហើយការយកថ្លៃសេវាសុខភាព ក៏ត្រូវបានណែនាំឲ្យប្រើនៅតាមកន្លែងថែទាំសុខភាពសាធារណៈទាំងឡាយទូទាំងប្រទេសកម្ពុជា (MOH 2007)។

កិច្ចប្រឹងប្រែងដើម្បីពន្លឿនការងើបឡើងវិញនៃ ប្រព័ន្ធសុខាភិបាលនៅជនបទ និងកែលំអការផ្តល់សេវាសុខភាព បាននាំឲ្យផុសឡើងនូវ ការចុះកិច្ចសន្យាលើសេវាសុខភាពសាធារណៈជាក់លាក់មួយចំនួន ក្នុងឆ្នាំ១៩៩៩។ ការចុះកិច្ចសន្យាសេវាសុខភាពនេះបានលូតលាស់ជាបីដំណាក់កាល។ ទី១ ពីឆ្នាំ១៩៩៩ ដល់ ២០០៣ ការចុះកិច្ចសន្យាម៉ៅការឲ្យខាងក្រៅ (external contracting) បានអនុវត្តសាកល្បងក្នុង ៥ស្រុកប្រតិបត្តិ (២ស្រុកសាកល្បងអនុវត្តការចុះកិច្ចសន្យាប្រភេទ contracting out និង ៣ស្រុកសាកល្បងអនុវត្តការចុះកិច្ចសន្យាប្រភេទ contracting in)។ ក្នុងអំឡុងពេលនោះ គេសង្កេតឃើញថា សេវាសុខភាពសុខាភិបាលមួយចំនួន ជាពិសេស សេវាសុខភាពមាតានិងទារកបានល្អប្រសើរឡើង ដែនគ្របដណ្តប់នៃសេវាសុខាភិបាលបានរីកធំ ហើយវិសមភាពនៃលទ្ធភាពទទួលបានសេវា និងចំណាយចេញពីហោប៉ៅអ្នកជំងឺលើសេវាសុខភាព បានធ្លាក់ចុះ ប៉ុន្តែវាមានតម្លៃខ្ពស់ជាងស្ទើរមួយជាពីរ បើធៀបនឹងស្រុកប្រតិបត្តិស្តង់ដារ (Bhushan et al. 2007)។

ដំណាក់កាលទី២ ក្នុងឆ្នាំ២០០៤-២០០៨ រួមមាន ការចុះកិច្ចសន្យា "កូនកាត់" ក្នុង ១៦ស្រុកប្រតិបត្តិ ក្នុងនោះមាន ១១ស្រុកប្រតិបត្តិ បានចុះកិច្ចសន្យាឲ្យអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិមួយចំនួនផ្តល់នូវសេវាផ្នែកគ្រប់គ្រង។ ក្នុងពេលជាមួយគ្នា ដោយទទួលបានជំនួយទ្រទ្រង់ពី ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសនៃប្រទេសប៊ែលហ្សិក ខាងមន្ទីរសុខាភិបាលខេត្តបានដាក់បញ្ចូល

---

អត្ថបទនេះរៀបចំឡើងដោយ វង្ស ស្រីទូច ជាអ្នកស្រាវជ្រាវផ្នែកសុខភាព នៃ CDRI, Joanna Raven សាស្ត្រាចារ្យផ្នែកប្រព័ន្ធសុខាភិបាល នៃ Liverpool School of Tropical Medicine និង David Newlands សាស្ត្រាចារ្យជាន់ខ្ពស់ផ្នែកសេដ្ឋកិច្ច នៅ Business School, Aberdeen University។ សូមយោងអត្ថបទនេះថា Vong Sreytouch, Joanna Raven and David Newlands. 2015. "Internal Contracting Cambodia Health Sector: Experience from Managers and Health Workers." Cambodia Development Review19(2):7-11. Phnom Penh: CDRI។

រូបភាព ១៖ ការវិវត្តនៃគោលនយោបាយសុខាភិបាលនៅកម្ពុជា




ប្រភព៖ ស្រង់ចេញពី MOH 2007; Ovesen and Trankell 2010

៥ស្រុកផ្សេងទៀត ទៅក្នុងកិច្ចសន្យាផ្អែកលើលទ្ធផល។ ផ្នែកសំខាន់ៗនៃគំរូទាំងពីរនេះរួមមាន កិច្ចសន្យាផ្អែកលើលទ្ធផល គ្រឿងលើកទឹកចិត្តនិងការត្រួតពិនិត្យ និងការកសាងសមត្ថភាពគ្រប់គ្រងផ្នែកសុខាភិបាលនៅតាមមូលដ្ឋាន (Keovathanak and Annear 2011; MOH 2007)។

ដំណាក់កាលទី៣វិវត្តឡើងរហូតដល់មានការបង្កើតទីភ្នាក់ងារប្រតិបត្តិការពិសេស (SOA) ដូចសព្វថ្ងៃ ពោលគឺ ជាទម្រង់មួយនៃកិច្ចសន្យាម៉ៅការផ្ទៃក្នុង ដែលកសាងឡើងបន្តពីកំណែទម្រង់រដ្ឋបាលសាធារណៈដ៏ធំទូលាយរបស់កម្ពុជា ដើម្បី កែលំអការផ្តល់សេវាកម្ម បង្កើនប្រាក់កម្រៃនិងការងារ កសាងសមត្ថភាពស្ថាប័ននិងធនធានមនុស្ស និងជំរុញការប្រើបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ (Vong 2013)។ នៅក្រោមការគ្រប់គ្រងរបស់ក្រសួងសុខាភិបាល កិច្ចសន្យា SOA មានដំណើរការនៅ ៤កម្រិត។ ក្រសួងសុខាភិបាល ចុះកិច្ចសន្យាជាមួយ មន្ទីរសុខាភិបាលខេត្តដែលដើរតួជាភ្នាក់ងារអនុវត្តការងារ។ មន្ទីរសុខាភិបាលខេត្ត ចុះកិច្ចសន្យាជាមួយស្រុកប្រតិបត្តិ ហើយស្រុកប្រតិបត្តិចុះកិច្ចសន្យាជាមួយ កន្លែងថែទាំសុខភាពនានាដែលនៅក្រោមការត្រួតត្រារបស់ខ្លួន។ បន្ទាប់មក អ្នកគ្រប់គ្រងកន្លែងថែទាំសុខភាពចុះកិច្ចសន្យាជាមួយបុគ្គលអ្នកផ្តល់សេវាថែទាំសុខភាព ឲ្យផ្តល់សេវាជាក់លាក់មួយចំនួន។ មាន ៣០ SOA បានកកើតឡើងនៅត្រឹមចុងឆ្នាំ២០១០ ហើយ ៦ ផ្សេងទៀត បានពង្រីកបន្ថែមនៅត្រឹមឆ្នាំ២០១៣ (MOH 2014)។ ចំណុចសំខាន់គឺ របៀបរបបចុះកិច្ចសន្យាម៉ៅការផ្ទៃក្នុងទាំងនេះ បានអនុញ្ញាតឲ្យមន្ទីរសុខាភិបាលខេត្តអាចចុះកិច្ចសន្យាជាមួយ SOAs ដោយផ្ទាល់។

មានការសិក្សាតិចតួចណាស់ ដែលបានផ្តោតលើលទ្ធផលនៃការអនុវត្ត SOA ។ គម្រោងនេះបានផ្តួចផ្តើមឡើងដើម្បីធ្វើជាមធ្យោបាយសម្រាប់កែលំអការផ្តល់សេវា និងគ្រប់គ្រងផ្នែកសុខភាពនៅតាមស្រុក (Khim and Annear 2013) ហើយអង្កេតថ្នាក់ជាតិតាមបែបបរិមាណមួយ បានធ្វើការប្រៀបធៀបការប្រើប្រាស់ កន្លែងថែទាំសុខភាពជា SOA និង មិនមែន SOA (World Bank 2013)។ ប៉ុន្តែមកទល់ពេលនេះ នៅមិនទាន់មានការវាយតម្លៃលើការយល់ឃើញរបស់បុគ្គលិកសុខាភិបាល អំពីគោលការណ៍ និងអត្ថប្រយោជន៍នៃ SOA នោះទេ។ ដូច្នេះ នៅមានកង្វះខាតការយល់ដឹងមួយចំនួនដែលត្រូវដោះស្រាយ។

ការយល់ដឹងពីការយល់ឃើញ កម្លាំងចិត្ត និងការពេញចិត្តរបស់បុគ្គលិកសុខាភិបាលអំពីបរិយាកាសការងាររបស់ខ្លួន វាចាំបាច់បំផុតដើម្បីកែលំអការរក្សាបុគ្គលិកសុខាភិបាល (Witter et al. 2011) និងលទ្ធផលនៃប្រព័ន្ធសុខាភិបាល (Chirdan et al. 2009)។ ដោយប្រើព័ត៌មានបានពីគម្រោង ReBUILD (ការស្រាវជ្រាវដើម្បីកសាង ប្រព័ន្ធសុខាភិបាលអំណោយផលដល់ជនក្រីក្រ ក្នុងពេលកសាងប្រទេសឡើងវិញបន្ទាប់ពីបានបញ្ចប់ទំនាស់) ស្តីពីការចុះកិច្ចសន្យាផ្នែកសុខាភិបាលនៅកម្ពុជា[1] អត្ថបទនេះពិនិត្យលើទិដ្ឋភាពបីយ៉ាងនៃកិច្ចសន្យាផ្តល់សេវា SOA៖ អត្ថប្រយោជន៍សម្រាប់បុគ្គលិកសុខាភិបាលម្នាក់ៗ ឥទ្ធិពលលើឥរិយាបថ និងអាកប្បកិរិយារបស់បុគ្គលិកសុខាភិបាល និងបញ្ហាប្រឈមក្នុងការបំពេញកាតព្វកិច្ចតាមកិច្ចសន្យា និងយុទ្ធសាស្ត្រសម្រាប់ដោះស្រាយ។

## វិធីសាស្ត្រស្រាវជ្រាវ

ស្របគ្នានឹងឯកសារមានស្រាប់ (ឧទាហរណ៍ ការសិក្សារបស់ Pope and Mays 1995; Malterud 2001) ការសិក្សានេះបានប្រើវិធីសាស្ត្រស្រាវជ្រាវបែបគុណភាព ដើម្បីទទួលបានព័ត៌មានស្តីពីការចុះកិច្ចសន្យា និងបង្ហាញពីបទពិសោធន៍ និងការយល់ឃើញរបស់បុគ្គលិកសុខាភិបាល។ ក្រុមស្រាវជ្រាវព្យាយាមពិនិត្យពីលទ្ធផលនៃការអនុវត្ត SOA តាមការយល់ឃើញរបស់អ្នកគ្រប់គ្រង និងបុគ្គលិកសុខាភិបាល ដើម្បីស្វែងយល់ពីទស្សនៈរបស់ពួកគេ (Bryman 1988)។ ក្នុងនេះមានការធ្វើសម្ភាសន៍ស៊ីជម្រៅ ចាប់ពីខែមីនា ដល់ មិថុនា ២០១៣ ជាមួយ អ្នកគ្រប់គ្រង និងបុគ្គលិកសុខាភិបាល ២៧នាក់ ក្នុង ៤ស្រុក SOA គឺ មេមត់ ពាំរាំង សំរោង និងបាទី។ ស្រុកទាំងនេះត្រូវបានជ្រើសរើស ដោយសារបច្ចុប្បន្នកំពុងមានជាប់ពាក់ព័ន្ធជាមួយគម្រោង SOA, មានបទពិសោធន៍ចុះកិច្ចសន្យាជាមួយ NGOs ពីមុនមក, មានទីតាំងភូមិសាស្ត្រសមស្រប និងមានការផ្តល់សេវាជាក់លាក់នានា (ឧទាហរណ៍ សេវាថែទាំសុខភាពកម្រិតបឋម ឬមធ្យម)។ មុននឹងធ្វើសម្ភាសន៍ អ្នកចូលរួមទទួលបានការរៀបរាប់ពីគោលបំណងនៃការសិក្សា និងបានចុះហត្ថលេខាយល់ព្រម ឲ្យមានការធ្វើសម្ភាសដោយស្ម័គ្រចិត្ត។ ការវិភាគក្របខ័ណ្ឌស្រាវជ្រាវ បានផ្តល់នូវវិធីសាស្ត្រមានលក្ខណៈជាប្រព័ន្ធ ម៉ត់ចត់ និងមានតម្លាភាពមួយសម្រាប់ការបកស្រាយ និងដាក់លេខកូដលើទិន្នន័យប្រមូលបាន (Ritchie et al. 2003)។ ប្រធានបទលេចចេញពីការធ្វើសម្ភាសន៍ដែលបានរំលេចឡើងនៅក្នុងកំណត់ត្រា ត្រូវបានចងក្រងផ្តុំជាកញ្ចុំៗសម្រាប់ធ្វើវិភាគលំអិត។

## លទ្ធផលស្រាវជ្រាវ

### *ការយល់ឃើញពីអត្ថប្រយោជន៍នៃការធ្វើការជាមួយ SOA*

អត្ថប្រយោជន៍ដែលរាយការណ៍ឡើងរួមមាន គ្រឿងលើកទឹកចិត្ត (ឧទាហរណ៍ ប្រាក់បន្ថែមលើបៀវត្សរ៍ និងប្រាក់បន្ថែមផ្សេងទៀត) ការបណ្តុះបណ្តាលនិងកសាងសមត្ថភាព ការពង្រឹងភាពជាម្ចាស់លើការគ្រប់គ្រងស្រុកប្រតិបត្តិ នីតិវិធីមានតម្លាភាពជាងមុន និងឱកាសអនុវត្តការងារជាឯកជន។

**គ្រឿងលើកទឹកចិត្ត និងប្រាក់បន្ថែម** ផ្តល់ឲ្យអ្នកគ្រប់គ្រង និងបុគ្គលិកសុខាភិបាល អាចមានបរិមាណតិច ប៉ុន្តែវាបំពេញបន្ថែមលើបៀវត្សរ៍ទាបរបស់មន្ត្រីរាជការ ដូច្នេះបានជួយទ្រទ្រង់ដល់ជីវភាពរបស់ពួកគាត់។ តាមសំដីរបស់បុគ្គលិកសុខាភិបាលម្នាក់ "អត្ថប្រយោជន៍សម្រាប់បុគ្គលិកនៅមណ្ឌលសុខភាព មានមិនច្រើនទេ ប៉ុន្តែវាជួយបំពេញបន្ថែមដល់ជីវភាពប្រចាំថ្ងៃ ដូច្នេះជាទឹកប្រាក់មួយយ៉ាងធំសម្រាប់ពួកគេ"។ បុគ្គលិកម្នាក់ទៀតមើលឃើញគ្រឿងលើកទឹកចិត្តទាំងនេះថាជា រង្វាន់ដល់ការប្តេជ្ញាចិត្ត

1 កម្មវិធី ReBUILD កំពុងអនុវត្តឡើងដោយអ្នកស្រាវជ្រាវមួយក្រុម ក្រោមជំនួយទ្រទ្រង់ផ្នែកហិរញ្ញវត្ថុពី ក្រសួងអភិវឌ្ឍអន្តរជាតិ នៃប្រទេសអង់គ្លេស (DfID)។ កម្មវិធីនេះ នឹងដំណើរការរហូតដល់ខែមីនា ២០១៧។

បម្រើវិជ្ជាជីវៈ៖ "ពួកយើងធ្វើការខ្លាំង ប៉ុន្តែក៏ទទួលបានគ្រឿងលើកទឹកចិត្តដែរ"។ ចំពោះយោបល់អវិជ្ជមានវិញ អ្នកឆ្លើយសម្ភាសន៍ខ្លះមានអារម្មណ៍ថា ការពឹងផ្អែកខ្លាំងពេកលើគ្រឿងលើកទឹកចិត្តផ្ដល់ឲ្យដោយ SOA អាចមានឥទ្ធិពលអវិជ្ជមាន ដោយធ្វើឲ្យខូចខាតដល់លទ្ធភាពរបស់បុគ្គលិកសុខាភិបាលក្នុងការធ្វើការដោយឯករាជ្យ៖ "វាមានចំណុចល្អខ្លះដែរ ប៉ុន្តែ "ក្នុងនេះយើងគ្រាន់តែអង្គុយ និងរង់ចាំលុយ ហើយមិនមានទឹកចិត្តក្នុងការប្រើប្រាស់គំនិតផ្ដួចផ្ដើមរបស់ខ្លួន និងធ្វើការងារដោយឯករាជ្យនោះទេ"។

**ឱកាសកសាងសមត្ថភាព** តាមរយៈ SOA: ទាំងអ្នកគ្រប់គ្រង និងបុគ្គលិកសុខាភិបាលបានអបអរសាទរ ហើយមានទំនុកចិត្តថា សមត្ថភាពរបស់គាត់បានកើនឡើងតាមនោះ។ កន្លែងថែទាំសុខភាពមួយចំនួន បានលៃចែកថវិកាដែលអ្នកគ្រប់គ្រងអាចប្រើប្រាស់វា សម្រាប់ផ្ដល់ការបណ្ដុះបណ្ដាលដល់បុគ្គលិកសុខាភិបាល។ អ្នកគ្រប់គ្រងមណ្ឌលសុខភាពម្នាក់បានប្រាប់ថា "តាមការចូលរួមក្នុង SOA យើងទទួលបានថវិកាច្រើនជាងមុនពីក្រសួងសុខាភិបាល ដើម្បីផ្ដល់ជាគ្រឿងលើកទឹកចិត្តដល់បុគ្គលិក និងផ្ដល់ការបណ្ដុះបណ្ដាលឲ្យពួកគេ"។ អ្នកឆ្លើយសម្ភាសន៍ដទៃទៀតបានបញ្ជាក់ថា បុគ្គលិកសុខាភិបាលឥឡូវមានឱកាសកសាងសមត្ថភាពច្រើនជាងមុន តាមរយៈវគ្គបណ្ដុះបណ្ដាលផ្សេងៗ៖ "អត្ថប្រយោជន៍នៃ SOA គឺ វាបានផ្ដល់វគ្គបណ្ដុះបណ្ដាលជាច្រើន។ បុគ្គលិកម្នាក់ៗសុទ្ធតែត្រូវបានបញ្ជូនឲ្យទៅចូលរួមវគ្គបណ្ដុះបណ្ដាលអ្វីមួយ។"

**ភាពជាម្ចាស់នៅថ្នាក់មូលដ្ឋាន លើការគ្រប់គ្រងស្រុកប្រតិបត្តិ** គេតែងគូសបញ្ជាក់ថាជា អត្ថប្រយោជន៍ដ៏សំខាន់មួយទៀតនៃគម្រោង SOA។ អ្នកគ្រប់គ្រងសេវាសុខភាព SOA មានឱកាសដឹកនាំ ធ្វើការដោយឯករាជ្យ សម្រេចចិត្តដោយខ្លួនឯង និងអនុញ្ញាតឲ្យមានម៉ោងពេលធ្វើការអាចបត់បែនបាន។ ពួកគេអាចមានគំនិតបែបថ្មីច្រើនជាងមុន មិនចាំបាច់គោរពតាមនីតិវិធីរឹងកំព្រឹស និងមានសិទ្ធិអំណាចលើបុគ្គលិកស្រុកប្រតិបត្តិ។ តួយ៉ាង ពួកគេអាចដោះស្រាយបញ្ហាខាងបុគ្គលិក និងពិន័យ ឬដាក់វិន័យលើបុគ្គលិកដែលអនុវត្តការងារមិនបានល្អ។ អ្នកគ្រប់គ្រងមួយរូប សង្កត់ធ្ងន់ថា "...ជាមួយនឹង SOA ស្រុកប្រតិបត្តិជាអ្នកឈានមុខគេ ហើយទទួលបន្ទុកលើការសម្រេចចិត្តគួរកែលំអសេវាបែបណាទៀត គឺខុសគ្នាពីរបៀបរបបចុះកិច្ចសន្យាកាលពីមុន។"

នីតិវិធីមានតម្លាភាព អាចសំគាល់បានថាជាលទ្ធផលវិជ្ជមានមួយ ជាពិសេសសម្រាប់ការគ្រប់គ្រងសេវាសុខភាពនៅតាមស្រុកប្រតិបត្តិ។ បុគ្គលិកសុខាភិបាលទាំងអស់ដែលបានឆ្លើយសម្ភាសន៍សុទ្ធតែបានយល់ដឹងពីកិច្ចសន្យា និងពីរបៀបគណនានិងការលៃចែកគ្រឿងលើកទឹកចិត្តក្នុងចំណោមអ្នកផ្ដល់សេវាទាំងឡាយ។

**កំហិតមានតិចជាងមុន លើការផ្ដល់សេវាថែទាំសុខភាពជាលក្ខណៈឯកជន** គឺជា ផលចំណេញមួយទៀត។ អ្នកគ្រប់គ្រង SOA មានសិទ្ធិអំណាចរៀបចំម៉ោងពេលធ្វើការឲ្យមានលក្ខណៈអាចបត់បែនបាន និងអនុម័តបទបញ្ជាអនុញ្ញាតនូវការផ្ដល់សេវាសុខភាពជាលក្ខណៈឯកជន នៅក្រៅម៉ោងធ្វើការដែលបានកំណត់។

> វាងាយស្រួលជាងមុនបន្តិច [នៅពេលចុះកិច្ចសន្យាជាមួយ NGOs]។ យើងអាចយកពេលទៅពិនិត្យអ្នកជំងឺរបស់យើងនៅខាងក្រៅបាន។ នៅពេលយើងរវល់នៅខាងក្រៅ យើងគ្រាន់តែជូនដំណឹងដល់ផ្នែករបស់យើង ដើម្បីឲ្យមានបុគ្គលិកមន្ទីរពេទ្យនៅប្រចាំការ។ យើងអាចទៅក្រៅមួយភ្លែត ដើម្បីទៅមើលផ្ទះ ដោយគ្រាន់តែសុំឲ្យអ្នករួមការងារម្នាក់មកប្រចាំការនៅកន្លែងយើង។ ប្រព័ន្ធបច្ចុប្បន្ន វាប្រសើរជាងមុនសម្រាប់បុគ្គលិក...

ទោះបីមានសេរីភាពក្នុងការរកចំណូលបន្ថែមតាមរយៈ ការផ្ដល់សេវាសុខភាពជាលក្ខណៈឯកជនក្ដី ក៏អ្នកឆ្លើយសម្ភាសន៍មួយចំនួនបានលើកថា គម្រោង SOA អាចបង្កើនការប្ដេជ្ញាចិត្តរបស់អ្នកមានវិជ្ជាជីវៈខាងសុខាភិបាល ក្នុងការបម្រើប្រព័ន្ធសុខភាពសាធារណៈដែរ។

> SOA មានផ្ដល់នូវគ្រឿងលើកទឹកចិត្ត ដូច្នេះបុគ្គលិកយើងអាចរកប្រាក់បានគ្រប់គ្រាន់ដោយមិនចាំបាច់ធ្វើការខាងក្រៅ [ផ្ដល់សេវាសុខភាពជាលក្ខណៈឯកជន]។ វាមានន័យថា បុគ្គលិករបស់យើងធ្វើការតែក្នុងមន្ទីរពេទ្យនេះប៉ុណ្ណោះ ហើយបានធ្វើឲ្យមន្ទីរពេទ្យយើងរឹងមាំឡើង។

## ឥទ្ធិពលនៃ SOA លើឥរិយាបថបុគ្គលិកសុខាភិបាល

អ្នកចូលរួមក្នុងការសិក្សា បានកត់សំគាល់នូវការប្រែប្រួលជាវិជ្ជមាន ក្នុងឥរិយាបថរបស់បុគ្គលិកសុខាភិបាលនៅតាមស្រុកដែលមាន SOA ជាពិសេស ការមកធ្វើការទាន់ពេលជាងមុន ការថយចុះអវត្តមានពីការងារ ការផ្ដល់សេវា ២៤ម៉ោងជាប់រហូត អាកប្បកិរិយាល្អជាងមុនចំពោះអ្នកជំងឺទាំងអ្នកធូរធារ និងអ្នកក្រ និងគុណភាពសេវាថែទាំសុខភាពល្អជាងមុន។

**ការគោរពបទបញ្ជាធ្វើការងារ** កំពុងក្លាយជាទម្លាប់ទូទៅមួយ។ បុគ្គលិកសុខាភិបាល មកធ្វើការទាន់ម៉ោងជាងមុន មានទំនួលខុសត្រូវនិងការប្ដេជ្ញាចិត្តបំពេញភារកិច្ចរបស់ខ្លួន រួមទាំងកាតព្វកិច្ចនៅប្រចាំការ ដើម្បីធានាសេវា ២៤ម៉ោង។ ការវិវត្តជាវិជ្ជមានទាំងនេះ ហាក់ជំរុញឡើងដោយ ការផ្ដល់ប្រាក់លើកទឹកចិត្តប្រចាំខែសម្រាប់ការមកធ្វើការ និងភាពទាន់ម៉ោង ដែលមានបញ្ជាក់ក្នុងកិច្ចសន្យា SOA ដូចមានបុគ្គលិកសុខាភិបាលម្នាក់បានអះអាងថា៖ "...បុគ្គលិកគោរពម៉ោងធ្វើការ នៅពេលជាប់កិច្ចសន្យាបម្រើការងារឲ្យ SOA។ ប្រសិនបើយើងខកមួយវេន ឬមកយឺត គេនឹងកាត់បន្ថយប្រាក់លើកទឹកចិត្តត្រូវបើកឲ្យយើង។"

**សេវាសុខភាព ២៤ម៉ោងជាប់រហូតនៅកន្លែងថែទាំសុខភាពសាធារណៈ**៖ បច្ចុប្បន្នឃើញមានកាន់តែទូទៅហើយ បើតាមរបាយការណ៍របស់អ្នកគ្រប់គ្រង និងបុគ្គលិកសុខាភិបាលនៅក្នុងតំបន់សិក្សានានា។ សេវា ២៤ម៉ោង ដែលបានផ្ដួចផ្ដើមឡើងនៅក្រោមរបបកិច្ចសន្យាកាលពីមុនៗ បានបន្តអនុវត្តនៅក្រោម SOA។ ប៉ុន្តែនៅស្រុកផ្សេងទៀត ដែលបុគ្គលិកតែងអវត្តមានជារឿយៗពីការងារ ជាពិសេសក្នុងវេនពេលល្ងាច និងយប់នោះ ការផ្ដល់សេវា ២៤ម៉ោង បានចាប់ផ្ដើមតាំងពីពេលមានគម្រោង SOA។ អ្នកចូលរួមក្នុងការសិក្សាយល់ថា ការផ្ដល់សេវាបានកាន់តែល្អនេះ វាកើតមានឡើងដោយសារមានបទបញ្ជាតឹងរឹងរបស់ SOA និងមានការ

យកថ្លៃសេវាពីអ្នកប្រើប្រាស់។ អ្នកចូលរួមមួយចំនួនពន្យល់ថា បុគ្គលិកសុខាភិបាល មានទឹកចិត្តបំពេញភារកិច្ចដែលបានកំណត់ និងផ្តល់សេវាសុខភាព ព្រោះពួកគេអាចរកចំណូលបានតាមការយកថ្លៃពីអ្នកប្រើប្រាស់សេវា៖ "[ពីមុនមិនមានសេវាអចិន្ត្រៃយ៍ ២៤ម៉ោងនៅទីនេះទេ] សេវាគឺត្រូវមាន ប៉ុន្តែគ្មានបុគ្គលិក" ពីមុនមានតែឈ្មោះ តែគ្មានបុគ្គលិកទេ។"

**អាកប្បកិរិយា និងឥរិយាបថចំពោះអ្នកជំងឺ** ៖ គេបានលើកថា វាមានលក្ខណៈល្អប្រសើរឡើង។ ការប្រែប្រួលស្រដៀងគ្នានេះក៏ឃើញមានដែរនៅក្រោមរបបកិច្ចសន្យាមុនៗ ប៉ុន្តែការងារជាមួយ SOA បានជំរុញឲ្យមានការរីកចម្រើនថែមទៀត។ ការប្រែប្រួលនេះត្រូវបានលើកឡើងថា បណ្តាលមកពី លក្ខខណ្ឌនៃកិច្ចសន្យាដែលមានដាក់បញ្ចូលនូវសូចនាករអាកប្បកិរិយា និងឥរិយាបថ ឲ្យជាប់ពាក់ព័ន្ធនឹងការផ្តល់ប្រាក់លើកទឹកចិត្ត។ អ្នកចូលរួមក្នុងការសិក្សាមួយចំនួនបានពន្យល់ថា បុគ្គលិកសុខាភិបាលចាប់ផ្តើមយល់ដឹងថា ការរួសរាយរាក់ទាក់ អាចជួយទាក់ទាញអ្នកជំងឺបានច្រើនជាងមុនមកកាន់កន្លែងថែទាំសុខភាពរបស់ខ្លួន ដូច្នេះពួកគេអាចមានឱកាសកាន់តែច្រើនដើម្បីបំពេញតាមគោលដៅដូចមានកំណត់នៅក្នុងកិច្ចសន្យា SOA។ អ្នកគ្រប់គ្រងកន្លែងថែទាំសុខភាពមួយបានលើកថា "យើងកាត់បន្ថយបានច្រើនណាស់នូវការស្តីកស្រពន់និងឥរិយាបថអាក្រក់របស់បុគ្គលិក ដូចជាការប្រើពាក្យសំដីមិនសមរម្យជាមួយអ្នកជំងឺ ជាដើម។ យើងបានផ្លាស់ប្តូរច្រើន។"

**គុណភាពនៃការថែទាំសុខភាព នៅតាមកន្លែងមាន SOA**៖ គេយល់ថា បានល្អប្រសើរឡើងចាប់ពីពេលមានការអនុវត្តគម្រោង SOA ។ បុគ្គលិកសុខាភិបាលមានការប្រយ័ត្នប្រយែង និងម៉ឺងម៉ាត់ជាងមុន ក្នុងការវាយតម្លៃសុខភាព និងព្យាបាលអ្នកជំងឺ។ នាបច្ចុប្បន្ន ពួកគេវាយតម្លៃលើរោគរបស់អ្នកជំងឺយ៉ាងល្អិតល្អន់ស្របតាម សេចក្តីណែនាំ កំណត់ត្រាលទ្ធផលរកឃើញ និងរោគវិនិច្ឆ័យប្រសើរជាងមុន ដោយពិនិត្យអ្នកជំងឺម្តងមួយនាក់ៗ និងចេញវេជ្ជបញ្ជា ឲ្យតែអ្នកជំងឺដែលបានមកពិនិត្យសុខភាពនៅក្នុងមន្ទីរពេទ្យប៉ុណ្ណោះ។ អ្នកចូលរួមក្នុងការសិក្សាបានផ្តល់ហេតុផលពីរលើការរីកចម្រើននេះ៖ ការពិនិត្យតាមដានជាទៀងទាត់លើការព្យាបាល និងកំណត់ត្រាសុខភាពរបស់អ្នកផ្តល់សេវា និងការផ្តល់ប្រាក់លើកទឹកចិត្តដល់ការផ្តល់សេវាថែទាំសុខភាពមានគុណភាពល្អ។ ខាងក្រោមនេះ ជាការឆ្លុះបញ្ចាំងខ្លះៗពីការផ្លាស់ប្តូរក្នុងការអនុវត្តផ្តល់សេវាសុខភាព៖

> ពីមុន ក្នុងពេលពិគ្រោះជំងឺ យើងគ្រាន់តែសួរសំណួរមួយចំនួនតូចប៉ុណ្ណោះ ហើយបន្ទាប់មក ចេញវេជ្ជបញ្ជាឲ្យ។ ប៉ុន្តែនៅក្រោមកិច្ចសន្យា SOA យើងត្រូវវាស់សម្ពាធឈាម និងកំដៅខ្លួន និងត្រូវកត់ត្រានៅលើកំណត់ត្រារបស់អ្នកជំងឺ...
>
> ប្រសិនបើអ្នកជំងឺគ្រុន យើងត្រូវធ្វើតេស្តឈាម មុនពេលអាចចេញវេជ្ជបញ្ជាឲ្យ។ មុនពេលមាន SOA យើងដើរផ្លូវកាត់ [សម្រាប់ការព្យាបាល]... មិនមានការត្រួតពិនិត្យពីថ្នាក់លើ មិនមានគ្រឿងលើកទឹកចិត្ត [យើង] ក៏ខ្ជិលតាមនឹងដែរ ហេតុដូច្នោះបានជា...

> នៅផ្នែករបស់ខ្ញុំ កាលពីមុនប្រសិនបើអ្នកជំងឺឈឺធម្មតានោះ យើងមិនបាច់ពិនិត្យរោគសញ្ញាអ្វីទេ។ ឧទាហរណ៍ មិនបាច់ធ្វើរោគវិនិច្ឆ័យអ្វីសម្រាប់ការឈឺក្បាលទេ។ ប៉ុន្តែឥឡូវយើងត្រូវធ្វើរោគវិនិច្ឆ័យលើអ្នកជំងឺឲ្យបានត្រឹមត្រូវ លើគ្រប់មុខជំងឺ ហើយយើងត្រូវកត់ត្រារោគវិនិច្ឆ័យលើកំណត់ត្រាសុខភាពរបស់អ្នកជំងឺ និងត្រូវចុះហត្ថលេខាទៀតផង-- ពីមុនយើងមិនធ្វើអញ្ចឹងទេ។ ឥឡូវ យើងត្រូវចុះហត្ថលេខាលើឯកសារជាច្រើនថែមទៀត។

ប៉ុន្តែមានបុគ្គលិកសុខាភិបាលខ្លះលើកថា គម្រោង SOA ដើរតួនាទីតិចតួចណាស់ក្នុងការកែលំអគុណភាពសេវាថែទាំសុខភាព ហើយការអនុវត្តតាមនីតិវិធីស្តង់ដារនិងក្រមសីលធម៌នោះបុគ្គលិកនានាបានជ្រួតជ្រាបរួចជាស្រេចតាមរយៈ ការចុះកិច្ចសន្យាកាលពីមុនៗជាមួយ NGOs។

## បញ្ហាប្រឈម និងយុទ្ធសាស្ត្រដោះស្រាយ

ការសម្រេចតាមគោលដៅកំណត់នៅក្នុងកិច្ចសន្យា SOA ត្រូវបានកំណត់ថាជា បញ្ហាប្រឈមចម្បងមួយដល់ការគ្រប់គ្រងសុខាភិបាលស្រុក។ អ្នកចូលរួមក្នុងការសិក្សាពន្យល់ថា ទោះបីខំប្រឹងប្រែងធ្វើការខ្លាំងហើយក្តី ក៏ពេលខ្លះនៅតែមិនអាចសម្រេចតាមគោលដៅបាន។ អ្នកចូលរួមជាច្រើននាក់មានការបារម្ភថា គេអាចកំណត់គោលដៅកាន់តែខ្ពស់ឲ្យពួកគាត់ រីឯខ្លះទៀតគិតថា គួរតែដំឡើងគោលដៅ ដើម្បីជំរុញឲ្យបុគ្គលិកសុខាភិបាលផ្តល់សេវាកាន់តែច្រើនឡើង ពីព្រោះប្រជាជនក៏កំពុងកើនចំនួនដែរ។

ការសិក្សា បានគូសបញ្ជាក់ពីហេតុផលមួយចំនួនដែលនាំឲ្យកន្លែងថែទាំសុខភាព ពិបាកបំពេញបានតាមគោលដៅកំណត់ក្នុងកិច្ចសន្យា។ ទី១ ការប៉ាន់ស្មានមិនបានត្រឹមត្រូវពីចំនួនប្រជាជនក្នុងស្រុកបានបង្កបញ្ហាដល់ការកំណត់គោលដៅ។ការសន្មតទូទៅមួយ គឺចំនួនប្រជាជនក្នុងស្រុកកំពុងកើនឡើង។ ប៉ុន្តែដូចដែលអ្នកគ្រប់គ្រងសុខាភិបាលបានរាយការណ៍ប្រាប់ដែរ ទំហំប្រជាជនទទួលរងឥទ្ធិពលពីចលនាចំណាកស្រុក ដូច្នេះ កំណើនចំនួនប្រជាជនអាចតូចជាងការរំពឹងទុក៖ "កំណើនចំនួនប្រជាជន [ក្នុងឃុំ] ត្រូវបានប៉ាន់ស្មានលើស ហើយជាក់ស្តែងវាទាបជាងការរំពឹងទុក ព្រោះមានប្រជាជនធ្វើចំណាកស្រុកទៅកាន់តំបន់ផ្សេង។"

ទី២ ទិន្នន័យមូលដ្ឋានដែលយកមកប្រើដើម្បីកំណត់គោលដៅ SOA មិនឆ្លុះបញ្ចាំងបានត្រឹមត្រូវទេពីការប្រើប្រាស់កន្លែងថែទាំសុខភាព។ តាមនេះ គោលដៅត្រូវបានកំណត់ក្នុងកម្រិតខ្ពស់ពេក ដូចមានអ្នកគ្រប់គ្រងផ្នែកសុខាភិបាលម្នាក់បានលើកថា "...នៅពេលធ្វើ [ចាប់ផ្តើម] វា ពួកគេមិនបានធ្វើការសិក្សាសម្រាប់ការប្រមូលទិន្នន័យមូលដ្ឋាននោះទេ ប៉ុន្តែគ្រាន់តែបានពិនិត្យផ្ទៀងផ្ទាត់លើភាពជាក់លាក់នៃទិន្នន័យ ដើម្បីយើងអាចទទួលយកតួលេខនេះ ឬតួលេខនោះប៉ុណ្ណោះ... ហេតុនេះ ពេលយើងចាប់ផ្តើម យើងប្រើប្រាស់ទិន្នន័យគ្មានសុពលភាព និងមិនអាចជឿជាក់បាន សម្រាប់ធ្វើជាមូលដ្ឋានរបស់យើង។"

ការប្រកួតប្រជែងក្នុងចំណោមមណ្ឌលសុខភាព ឬកន្លែងផ្តល់សេវាដើម្បីទាក់ទាញអ្នកជំងឺក្នុងស្រុក ជាហេតុផលទី៣ នៃការមិនអាចបំពេញបានតាមគោលដៅ។ អ្នកចូលរួមក្នុងការសិក្សាមួយចំនួនប្រាប់ថា កន្លែងថែទាំសុខភាពនីមួយៗមានគោលដៅជាក់លាក់របស់ខ្លួនផ្ទាល់។ ប៉ុន្តែដោយអ្នកជំងឺមានចំនួនតិច

ដូច្នេះមណ្ឌលសុខភាព ឬកន្លែងផ្តល់សេវាមិនអាចសម្រេចតាមគោលដៅរបស់ខ្លួនទាំងអស់គ្នាបានឡើយ ហើយលើចំណុចនេះ ប្រធានមណ្ឌលសុខភាពមួយកន្លែងបានលើកថា៖

> បញ្ហាចម្បងនៅកន្លែងខ្ញុំ គឺផ្នែកជំងឺខាងក្រៅមានការប្រើប្រាស់មិនបានពេញលេញ។ ប្រជាជនតែងទៅកាន់កន្លែងថែទាំសុខភាពនៅជិតជាងគេបំផុត ហើយកន្លែងទាំងនោះតែងប្រឹងរក្សាទុកអ្នកជំងឺរបស់ខ្លួន ព្រោះពួកគេក៏មានសូចនាករគោលដៅត្រូវបំពេញដែរ។ សរុបមក ចំនួនប្រជាជននៅជុំវិញនេះគ្មានការប្រែប្រួលទេ ប៉ុន្តែ មានមណ្ឌលសុខភាពច្រើនជាងមុនដែលព្យាយាមទាក់ទាញប្រជាជន ឲ្យប្រើសេវានៅកន្លែងគេ។

យុទ្ធសាស្រ្តសម្រាប់បំពេញតាមគោលដៅនៃកិច្ចសន្យា ដែលអ្នកចូលរួមបានរាយការណ៍ឡើង ក្នុងការសិក្សានៅក្នុងតំបន់ទាំងបួន តែងមាន សកម្មភាពផ្សព្វផ្សាយនៅតាមសហគមន៍ជារៀងរាល់ខែ។ក្នុងនេះបុគ្គលិកសុខាភិបាលទៅជួបអ្នកជំងឺដល់ផ្ទះ ដើម្បីផ្តល់ការពិគ្រោះជំងឺ ត្រួតពិនិត្យផ្ទៃពោះ និងចែកឱសថ។ ការចុះជួបផ្ទាល់នេះ ជួយជំរុញនូវការរាយការណ៍ទិន្នន័យ ដើម្បីបំពេញតាមគោលដៅ។ ប៉ុន្តែក្នុងការងារនេះ មានបញ្ហាប្រឈមជាច្រើន។ ដោយឡែកកង្វះខាតបុគ្គលិកមណ្ឌលសុខភាពមានន័យថាមានតែបុគ្គលិកផ្នែកផ្តល់ថ្នាំបង្ការប៉ុណ្ណោះ ដែលអាចចុះទៅសហគមន៍បាន។ ជារឿយៗ មណ្ឌលសុខភាពក៏មានការងាររមមាញឹកពេកមិនអាចរំលែកបុគ្គលិកឲ្យចុះទៅសហគមន៍បានឡើយ។

## សេចក្តីសន្និដ្ឋាន

សរុបមក លទ្ធផលសិក្សាឆ្លុះបញ្ចាំងនូវទស្សនៈវិជ្ជមានក្នុងចំណោមអ្នកគ្រប់គ្រង និងបុគ្គលិកសុខាភិបាលដែលធ្វើការក្រោមកិច្ចសន្យាផ្តល់សេវា SOA។ ប៉ុន្តែគេមិនអាចធ្វើការសន្និដ្ឋានជាទូទៅពីអត្ថប្រយោជន៍ និងឥទ្ធិពលនៃ SOA ដោយគ្រាន់តែផ្អែកលើការសិក្សាពីការយល់ឃើញតែមួយមុខបានទេ។ ទោះយ៉ាងណាក្តី ការសិក្សានេះផ្តល់នូវការយល់ដឹងដ៏មានប្រយោជន៍អំពីទស្សនៈ និងបទពិសោធន៍របស់អ្នកគ្រប់គ្រង និងអ្នកផ្តល់សេវាធ្វើការជាមួយ SOA ដែលអាចរួមចំណែកបង្កើនការយល់ដឹងអំពីកត្តានានាដែលជះឥទ្ធិពលទៅលើទឹកចិត្ត និងការពេញចិត្តបំពេញការងាររបស់បុគ្គលិកសុខាភិបាល។ តាមនេះ ការសិក្សាអាចផ្តល់ជាព័ត៌មានដល់អន្តរាគមន៍នៅថ្ងៃមុខទៀត ដើម្បីជួយកែលំអការផ្តល់សេវាសុខភាព និងការរក្សាបុគ្គលិកសុខាភិបាលនៅថ្នាក់ក្រោមជាតិ។

## ឯកសារយោង


Bhushan, Indu. Erik Bloom, David Clingingsmith, Rathavuth Hong, Elizabeth King, Michael Kremer, Benjamin Loevinsohn and J. Brad Schwartz. 2007. "Contracting for Health: Evidence from Cambodia." Accessed 30 Nov 2012, www.brookings.edu/views/papers/ kremer/20060720cambodia.pdf.

Bryman, Alan, ed.1988. *Doing Research in Organizations*. London: Routledge.

Chirdan, O.O., J.T. Akosu, C.L. Ejembi, A.P.Bassi and A.I. Zoakah. 2009. "Perceptions of Working Conditions amongst Health Workers in State-owned Facilities in Northeastern Nigeria."*Annals of African Medicine* 8(4): 243-249. doi: 10.4103/1596-3519.59579.

Keovathanak, Khim, and Peter Leslie Annear. 2011. " The Transition to Semi-Autonomous Managment of District Health Services in Cambodia: Assessing Purchasing Arrangements, Transaction Costs and Operational Efficiencies of Special Operating Agencies."*Improving Health Sector Performance: Institutions, Motivations and Incentives – The Cambodia Dialogue,* edited by Hossein Jalilian and Vicheth Sen, 45-75. Singapore: ISEAS.

Khim, Khim, and Peter Leslie Annear. 2013. "Strengthening District Health Service Management and Delivery through Internal Contracting: Lessons from Pilot Projects in Cambodia." *Social Science & Medicine* 96: 241-249.

Malterud, K. 2001. "Qualitative Research: Standards, Challenges, and Guidelines."*Lancet* 358(9280): 483-488.

MOH (Ministry of Health). 2007. *Cambodia Health Information System: Review and Assessment*. Phnom Penh: MOH.

MOH. 2014. *Annual Heath Financing Report 2014*. Phnom Penh: MOH.

Ovesen, Jan, and Ing-Britt Trankell. 2010. *Cambodians and Their Doctors: A Medical Anthropology of Colonial and Postcolonial Cambodia*. Copenhagen: NIAS.

Pope, Clive C., and Nicholas Barron Mays.1995. "Qualitative Research: Reaching the Parts Other Methods Cannot Reach: An Introduction to Qualitative Methods in Health and Health Services Research."*British Medical Journal* 311:42-45.

Ritchie, Jane, and Jane Lewis, eds. 2003. *Qualitative Research Practice: A Guide for Social Science Students and Researchers.* London: Sage Publications.

Vong Sreytouch. 2013. "Contracting Arrangements in Cambodia's Health Sector – Some Trends."*Annual Development Review 2012-13*, 33-42. Phnom Penh: CDRI.

Witter, Sophie, Bui Thi Thu Ha, Bakhuti Shengalia and Marko Vujicic. 2011. "Understanding the 'Four Directions of Travel': Qualitative Research into the Factors Affecting Recruitment and Retention of Doctors in Rural Vietnam." *Human Resources for Health* 9(1). Accessed 8 Jul 2015, www.human-resources-health.com/content/9/1/20.

World Bank. 2013. *Cambodia 's Rural Health Markets.* Washington, DC: World Bank, Human Development Unit & East Asia and Pacific Region.

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស

ផ្នែកនេះពិពណ៌នាពីសេដ្ឋកិច្ចនៅប្រទេសធំៗមួយចំនួន និងនៅអាស៊ីអាគ្នេយ៍។ នៅត្រីមាសទី១ ឆ្នាំ២០១៥ សេដ្ឋកិច្ចនៅបណ្ដាប្រទេសអាស៊ាន មានដំណើរការល្អ លើកលែងតែនៅ ឥណ្ឌូនេស៊ី និងម៉ាឡេស៊ី។ អត្រាកំណើន ផសស ប្រចាំឆ្នាំ នៅឥណ្ឌូនេស៊ី ធ្លាក់ចុះ ០,៧ឯកតាភាគរយ ហើយនៅម៉ាឡេស៊ី ធ្លាក់ចុះ ០,២ឯកតាភាគរយ ធៀបនឹងត្រីមាសមុន។ អត្រាកំណើន ផសស ពិត នៅសិង្ហបុរី កើន ០,៥ឯកតាភាគរយ និងនៅថៃ កើន ១,១ឯកតាភាគរយធៀបនឹងត្រីមាសមុន។

នៅត្រីមាសទី១ កំណើន ផសស ពិតនៅចិន មានអត្រាមធ្យម ៧,០% ប៉ុន្តែនៅហុងកុង វាធ្លាក់ចុះមកត្រឹម ២,១% ហើយនៅកូរ៉េខាងត្បូង ធ្លាក់មក ២,៤%។ កំណើន ផសស ក្នុងពេល ១២ខែ នៅតៃវ៉ាន់ មានអត្រា ៣,៤% ធៀបនឹង ៣,១% កាលពីមួយឆ្នាំមុន។

អត្រាកំណើនពិតនៅតំបន់អឺរ៉ូ កើនដល់ ១,០%។ អត្រានេះធ្លាក់ចុះមកត្រឹម ០,៩% នៅជប៉ុន ទោះបីប្រាក់យេនបានធ្លាក់ថ្លៃ ដែលនាំឲ្យមានកំណើនការនាំចេញ និង កំណើន ផសស ០,១ឯកតាភាគរយក្ដី។ សហរដ្ឋអាមេរិក សម្រេចបានកំណើនខ្លាំងដល់ ២,៧% ឬ ខ្ពស់ជាងមួយឆ្នាំមុន ០,៤ឯកតាភាគរយ។ ការនាំចេញ និង ចំណាយរដ្ឋាភិបាលមូលដ្ឋាន និង ចំណាយរដ្ឋ ក៏បានរួមចំណែកជំរុញកំណើន ផសស ដែរ។

## អតិផរណា

នៅត្រីមាសទី១ អតិផរណាក្នុងប្រទេសជឿនលឿន និង ប្រទេសមានសេដ្ឋកិច្ចកំពុងស្ទុះឡើង មានតួលេខត្រឹមមួយខ្ទង់។ អតិផរណា ធ្លាក់មកត្រឹម ១,០% នៅកម្ពុជា ធៀបនឹង ២,២% កាលពីត្រីមាសមុន។ នៅត្រីមាសទី១ អតិផរណាប្រចាំឆ្នាំ មានអត្រា ៦,៦% នៅឥណ្ឌូនេស៊ី និង ០,៧% នៅម៉ាឡេស៊ី។ សិង្ហបុរីបានជួបបរិត្តផរណា ក្នុងពីរត្រីមាសចុងក្រោយ ដោយសារមានការធ្លាក់ថ្លៃសម្លៀកបំពាក់ ស្បែកជើង និងកន្លែងស្នាក់នៅ។ អតិផរណានៅវៀតណាម មានត្រឹម ០,៧% ដែលជាអត្រាទាបបំផុតក្នុងរយៈពេល ៩ឆ្នាំកន្លងទៅ។ ការថយចុះនេះ បណ្ដាលមកពីការធ្លាក់ចុះថ្លៃប្រេងនៅលើពិភពលោក។ អតិផរណាប្រចាំឆ្នាំ ធ្លាក់ចុះមកត្រឹម ១,២% នៅចិន ៤,៤% នៅហុងកុង និង ០,៦% នៅកូរ៉េខាងត្បូង។ អតិផរណានៅតៃវ៉ាន់ កើនដល់ ២,៩% ដែលជាអត្រាខ្ពស់បំផុតក្នុងរយៈពេល ៧ឆ្នាំកន្លងទៅ។ អតិផរណានៅតំបន់អឺរ៉ូ និងសហរដ្ឋអាមេរិក ធ្លាក់ចុះ ០,៣% និង ០,៤% រៀងគ្នា។ អតិផរណាប្រចាំឆ្នាំនៅជប៉ុន មានកម្រិតទាបដដែល ត្រឹម ២,៣% ឬធ្លាក់ចុះ ០,៣ឯកតាភាគរយ បើធៀបនឹងត្រីមាសមុន។

## ថ្លៃទំនិញនៅលើទីផ្សារពិភពលោក

នៅត្រីមាសទី១ ឆ្នាំ២០១៥ ទំនិញសំខាន់ៗក្នុងទីផ្សារពិភពលោកបានធ្លាក់ថ្លៃ ធៀបនឹងត្រីមាសមុន។ ប្រេងឆាធ្លាក់ថ្លៃ ១២,២% មកត្រឹម ៦២៧,៩ដុល្លារ/តោន កៅស៊ូធ្លាក់ថ្លៃ ៥,៧% មកត្រឹម ១៤៥០,២ដុល្លារ/តោន ហើយអង្ករធ្លាក់ថ្លៃ ១,០% មកត្រឹម ៤២៦,០ដុល្លារ/តោន។ សណ្ដែកសៀង ធ្លាក់ថ្លៃ ១៧,២% មកត្រឹម ៣៦៣,៩ដុល្លារ/តោន ហើយប្រេងឆៅ ធ្លាក់ថ្លៃ ៣០,៧% មកត្រឹម ៥០,៩ដុល្លារ/ធុង។ សាំងធ្លាក់ថ្លៃ ១៧,០% មកត្រឹម ០,៤០ដុល្លារ/លីត្រ ហើយ ម៉ាស៊ូតធ្លាក់ថ្លៃ ២២,៤% មកត្រឹម ០,៤៥ដុល្លារ/លីត្រ។

អត្ថបទនេះ រៀបរៀងដោយលោកស្រី ស្រ៊ី បុប្ផារ័ត្ន និងលោកស្រី ប៊ុន ដូរីណា ជាជំនួយការស្រាវជ្រាវ នៅវិទ្យាស្ថាន CDRI។

តារាង១. កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៧-២០១៥ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 10.2 | 6.7 | 0.1 | 6.0 | 7.1 | 7.3 | 7.4 | - | - | - | - | - |
| ឥណ្ឌូណេស៊ី | 6.3 | 6.1 | 4.2 | 6.2 | 6.5 | 6.3 | 5.8 | 5.2 | 5.1 | 5.0 | 5.4 | 4.7 |
| ម៉ាឡេស៊ី | 6.3 | 4.6 | -2.4 | 9.0 | 4.9 | 5.4 | 4.6 | 6.2 | 6.4 | 5.6 | 5.8 | 5.6 |
| សិង្ហបុរី | 7.7 | 1.1 | -4.5 | 14.7 | 4.7 | 1.3 | 3.8 | 5.1 | 2.4 | 2.4 | 2.1 | 2.6 |
| ថៃ | 4.9 | 2.6 | 3.3 | 7.9 | 0.0 | 6.7 | 2.8 | 3.1 | 0.3 | 0.6 | 2.2 | 3.3 |
| វៀតណាម | 8.5 | 6.2 | 4.7 | 6.4 | 6.2 | 5.2 | 5.4 | - | - | - | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 11.9 | 9.0 | 8.2 | 10.4 | 9.3 | 7.7 | 7.7 | 7.1 | 7.5 | 7.3 | 7.3 | 7.1 |
| ហុងកុង | 6.4 | 2.4 | -3.2 | 6.9 | 4.9 | 2.9 | 3.0 | 2.5 | 1.8 | 2.7 | 2.2 | 2.1 |
| កូរ៉េខាងត្បូង | 4.9 | 2.2 | -1.0 | 6.1 | 3.6 | 2.1 | 2.8 | 4.1 | 3.5 | 3.2 | 2.8 | 2.4 |
| តៃវ៉ាន់ | 5.2 | 0.1 | -3.6 | 11.1 | 4.2 | 1.2 | 2.2 | 3.1 | 3.7 | 3.8 | 3.3 | 3.4 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 2.9 | 0.9 | -3.8 | 1.6 | 1.6 | -0.5 | 0.1 | 0.9 | 0.7 | 0.3 | 0.9 | 1.0 |
| ជប៉ុន | 2.0 | -0.7 | -5.4 | 4.1 | -0.8 | 1.7 | 1.7 | 3.1 | -0.1 | -1.2 | 0.5 | -0.9 |
| សហរដ្ឋអាមេរិក | 2.2 | 1.1 | -2.5 | 2.7 | 1.8 | 2.1 | 1.8 | 2.3 | 2.6 | 2.3 | 2.4 | 2.7 |

Sources: International Monetary Fund, Economist and countries' statistic offices

តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៧-២០១៥ (កំណើនថ្លៃជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 10.5 | 19.7 | -0.5 | 4.1 | 5.5 | 3.0 | 3.0 | 4.5 | 4.9 | 4.0 | 2.2 | 1.0 |
| ឥណ្ឌូណេស៊ី | 6.4 | 10.1 | 4.7 | 5.1 | 5.4 | 4.3 | 7.0 | 7.7 | 7.1 | 4.3 | 6.5 | 6.6 |
| ម៉ាឡេស៊ី | 2.0 | 5.3 | 0.4 | 1.7 | 3.2 | 1.7 | 2.1 | 3.5 | 3.3 | 3.0 | 2.8 | 0.7 |
| សិង្ហបុរី | 2.1 | 6.5 | 0.5 | 2.9 | 5.2 | 4.6 | 2.3 | 1.0 | 2.3 | 0.9 | -0.1 | -0.3 |
| ថៃ | 2.2 | 5.5 | -0.9 | 3.1 | 3.8 | 3.0 | 2.2 | 2.0 | 2.5 | 2.0 | 1.1 | -0.5 |
| វៀតណាម | 8.3 | 23.3 | 7.3 | 9.0 | 18.6 | 9.3 | 6.6 | 4.8 | 4.7 | 4.5 | 5.4 | 0.7 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 4.8 | 5.9 | -0.8 | 3.2 | 5.4 | 2.7 | 2.6 | 2.1 | 2.2 | 2.0 | 1.5 | 1.2 |
| ហុងកុង | 2.0 | 4.3 | -0.3 | 2.4 | 5.3 | 4.1 | 4.0 | 4.1 | 3.6 | 4.9 | 5.0 | 4.4 |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| កូរ៉េខាងត្បូង | 2.5 | 4.6 | 2.8 | 3.0 | 4.4 | 2.1 | 1.1 | 1.1 | 1.6 | 1.4 | 1.0 | 0.6 |
| តៃវ៉ាន់ | 1.8 | 3.2 | -1.1 | 1.0 | 1.4 | 1.9 | 0.8 | 1.1 | 1.6 | 1.5 | 1.6 | 2.9 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 2.1 | 3.3 | 0.4 | 1.6 | 2.7 | 2.5 | 1.4 | 0.6 | 0.6 | 0.4 | 0.2 | -0.3 |
| ជប៉ុន | 0.1 | 1.4 | -1.3 | -0.7 | 0.1 | -0.03 | 0.4 | 1.5 | 3.6 | 3.4 | 2.6 | 2.3 |
| សហរដ្ឋអាមេរិក | 2.9 | 3.8 | -0.4 | 1.7 | 3.2 | 2.1 | 1.5 | 1.4 | 2.1 | 1.8 | 1.3 | -0.4 |

Sources: International Monetary Fund, Economist and National Institute of Statistics

តារាង៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារអាមេរិកនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៧-២០១៥ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា (រៀល) | 4062.7 | 4054.2 | 4140.5 | 4187.1 | 4063.6 | 4037.8 | 5369.6 | 3993.8 | 4026.9 | 4059.5 | 4070.1 | 4042.2 |
| ឥណ្ឌូណេស៊ី (រូពីយ៉ា) | 9419 | 9699 | 10,413.8 | 9089.9 | 4374.0 | 9363.0 | 13892.2 | 11,765.8 | 11,615.3 | 11,775.7 | 12,244.1 | 12,809.9 |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.3 | 3.3 | 3.5 | 3.2 | 1.5 | 3.1 | 4.2 | 3.3 | 3.2 | 3.2 | 3.4 | 3.6 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.51 | 1.42 | 1.5 | 1.4 | 1.3 | 1.2 | 1.7 | 1.3 | 1.3 | 1.3 | 1.3 | 1.4 |
| ថៃ (បាត) | 32.22 | 33.36 | 34.3 | 31.7 | 30.5 | 31.1 | 41.0 | 32.6 | 32.4 | 32.1 | 32.7 | 32.6 |
| វៀតណាម (ដុង) | 16,030.0 | 16,382 | 17,725.2 | 19,200.8 | 20,574.3 | 20,856.9 | 27,987.1 | 21,093.8 | 20,923.2 | 21,221.9 | 21,314.0 | 21,372.9 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន (យ៉ន់) | 8.03 | 6.94 | 6.8 | 6.8 | 6.5 | 6.3 | 8.2 | 6.1 | 6.2 | 6.2 | 6.1 | 6.2 |
| ហុងកុង (ដុល្លារហុងកុង) | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 10.3 | 7.8 | 7.8 | 7.8 | 7.8 | 7.8 |
| កូរ៉េខាងត្បូង (វ៉ុន) | 929.0 | 1137.2 | 1277.8 | 1156.3 | 1108.6 | 1126.6 | 1460.0 | 1069.7 | 1028.9 | 1027.5 | 1088.4 | 1101.7 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 32.9 | 31.5 | 33.0 | 31.3 | 29.4 | 29.6 | 39.6 | 30.3 | 30.1 | 30.0 | 30.9 | 31.6 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 0.7 | 0.8 | 0.7 | 0.8 | 0.7 | 0.8 | 1.0 | 0.7 | 0.7 | 0.8 | 0.8 | 0.9 |
| ជប៉ុន (យ៉េន) | 117.8 | 102.5 | 93.6 | 87.8 | 79.9 | 79.8 | 130.2 | 102.8 | 102.1 | 104.0 | 114.6 | 119.2 |

Sources: International Monetary Fund, Economist and National Bank of Cambodia

តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០៧-២០១៥ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 Q1 | Q2 | Q3 | Q4 | 2015 Q1 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ពោត (US No. 2) - USA (USD/តោន) | 163.7 | 223.1 | 165.5 | 185.9 | 291.7 | 298.4 | 259.4 | 209.9 | 214.0 | 174.1 | 173.5 | 174.2 |
| ប្រេងឆា-អឺរ៉ុបពាយព្យ (USD/តោន) | 780.3 | 948.5 | 682.8 | 900.8 | 1125.4 | 999.3 | 856.9 | 911.3 | 887.1 | 772.0 | 715.3 | 627.9 |
| កៅស៊ូ SMR 5 (USD/តោន) | 0.0 | 1431.6 | 1884.8 | 3405.7 | 4630.6 | 3200.7 | 2575.3 | 2034.7 | 1777.6 | 1672.1 | 1538.1 | 1450.2 |
| អង្ករ (Thai 100%B) - បាងកក (USD/តោន) | 305.4 | 615.3 | 524.5 | 506.6 | 558.5 | 594.8 | 533.8 | 450.7 | 411.7 | 447.0 | 430.3 | 426.0 |
| សណ្តែកសៀង (US No. 1) - USA (USD/តោន) | 384.0 | 522.8 | 436.9 | 449.8 | 540.7 | 591.4 | 538.4 | 552.3 | 517.8 | 457.3 | 439.7 | 363.9 |
| ប្រេងឆៅ - OPEC spot (USD/ធុង) | 66.8 | 99.4 | 57.7 | 76.8 | 106.2 | 109.5 | 105.9 | 104.7 | 105.9 | 100.8 | 73.4 | 50.9 |
| សាំង - US Gulf Coast (សេន/លីត្រ) | 52.2 | 68.1 | 40.8 | 53.3 | 71.9 | 74.6 | 71.2 | 70.1 | 74.1 | 70.0 | 48.3 | 40.1 |
| ម៉ាស៊ូត (ស្តាន់ដ័រតិច លេខ២) - US Gulf Coast (សេន/លីត្រ) | 55.5 | 76.2 | 43.0 | 56.1 | 75.7 | 80.7 | 78.4 | 77.5 | 77.1 | 73.7 | 57.5 | 44.6 |

Sources: Food and Agriculture Organisation and US Energy Information Administration

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្នុងប្រទេស

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

នៅត្រីមាសទី១ អនុមតិវិនិយោគគិតជាទ្រព្យសកម្មជាប់លាប់ កើន ១៨១៦,៨% ធៀបត្រីមាសមុន និង ៥៧៣,០% ធៀបមួយឆ្នាំមុន ដល់ ២៨៧៣,២លានដុល្លារ។ វិនិយោគក្នុងវិស័យកាត់ដេរ មានចំណែក ១៨,៦% នៃគម្រោងសរុប ដោយបានកើនឡើង ១១០,៨% ធៀបត្រីមាសមុន ដល់ ៦៣,៩លានដុល្លារ។ វិនិយោគក្នុងវិស័យកសិកម្ម កើនពីកម្រិតសូន្យ ដល់ ២៥,៨លានដុល្លារ។ វិនិយោគក្នុងវិស័យសេវាកម្ម មានចំណែក ៨៧% ក្នុងអនុមតិគម្រោងសរុប ហើយកំណើនដ៏ធំនេះបានមកពីការរួមចំណែកនៃអនុវិស័យទេសចរណ៍ និងសណ្ឋាគារ ៦០,៦លានដុល្លារ, អនុវិស័យទូរគមនាគមន៍ ២៧០,១លានដុល្លារ និងអនុវិស័យផ្សេងទៀត ២១៧១,២លានដុល្លារ។

នៅត្រីមាសទី១ ឆ្នាំ២០១៥ ភ្ញៀវទេសចរមកដល់កម្ពុជាសរុប កើន ៥,៤% ធៀបត្រីមាសមុន។ ភ្ញៀវមកដល់តាមផ្លូវអាកាស កើន ១៣,៥% ប៉ុន្តែភ្ញៀវមកដល់តាមផ្លូវគោក និងផ្លូវទឹក ធ្លាក់ចុះ ២,៥%។ ក្នុងរយៈពេល ៥ត្រីមាសជាប់ៗគ្នាកន្លងទៅ ចំនួនភ្ញៀវទេសចរមកកម្ពុជា កើនក្នុងអត្រាលេខមួយខ្ទង់។

អត្ថបទនេះ រៀបរៀងដោយលោកស្រី ស្រ៊ី បុប្ផារ័ត្ន និងលោកស្រី ប៊ុន ដូរីណា ជាជំនួយការស្រាវជ្រាវ នៅវិទ្យាស្ថាន CDRI។

ការនាំចេញសរុប កើន ១,៥% ធៀបនឹងត្រីមាសមុន និង ៩,៨% ធៀបនឹងឆ្នាំមុន។ ការនាំចេញសម្លៀកបំពាក់ កើន ៣,៨% ដល់ ១៥៤៨,៨លានដុល្លារ ធៀបនឹង ១៤៩២,៦លានដុល្លារ កាលពីត្រីមាសមុន។ សហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប នៅតែជាទីផ្សារចម្បងសម្រាប់ផលិតផលសម្លៀកបំពាក់ ដោយមានចំណែក ៣២% និង ៤០% រៀងគ្នា។ ទោះយ៉ាងណាក្តី ការនាំចេញទៅសហភាពអឺរ៉ុប រួមចុះ ៣,៣% បើធៀបនឹងត្រីមាសមុន។ ការនាំចេញសម្លៀកបំពាក់ទៅប្រទេសសមាជិកអាស៊ាន កើន ១៤,១% និងទៅជប៉ុន កើន ៣៦,១% ប៉ុន្តែការនាំចេញទៅប្រទេសទាំងនេះ រួមចំណែកត្រឹមតែ ១,៦% និង ៧,៨% រៀងគ្នាក្នុងការនាំចេញសរុបប៉ុណ្ណោះ។

នៅត្រីមាសទី១ ដដែល ការនាំចេញផលិតផលកសិកម្ម ធ្លាក់ចុះ ៩,៦% ធៀបត្រីមាសមុន និង ១០% ធៀបឆ្នាំមុន។ អង្ករ និងកៅស៊ូ ជាផលិតផលកសិកម្មចម្បងគេ ដោយមានចំណែក ២៨% និង ៦០% រៀងគ្នាក្នុងផលិតផលកសិកម្មនាំចេញសរុប។ ធៀបនឹងត្រីមាសមុន ការនាំចេញកៅស៊ូ ធ្លាក់ចុះ ១២,២% មកត្រឹម ៤១,៧លានដុល្លារ ហើយការនាំចេញត្រី ធ្លាក់ចុះ ២៨,៦% រីឯការនាំចេញផលិតផលកសិកម្មផ្សេងទៀត ធ្លាក់ចុះ ៨១,៩% ប៉ុន្តែការនាំចេញអង្ករ កើន ៩,០% ដល់ ៨៩,៥លានដុល្លារ ហើយការនាំចេញឈើ កើន ៧០,១% ដល់ ១៣,៩លានដុល្លារ។

នៅត្រីមាសទី១ ការនាំចូលសរុបធ្លាក់ចុះ ៣,២% ធៀបត្រីមាសមុន ប៉ុន្តែកើន ២១,៤% ធៀបឆ្នាំមុន ដល់ ២៧១៧,៣លានដុល្លារ។ ការនាំចូលសាំងធ្លាក់ចុះ ៦,៣% រីឯការនាំចូលម៉ាស៊ូតកើន ១១,៩% ហើយការនាំចូលសម្ភារសំណង់កើន ៨,៥% ធៀបនឹងត្រីមាសមុន។

## ហិរញ្ញវត្ថុសាធារណៈ

នៅត្រីមាសទី១ ចំណូលរដ្ឋាភិបាលសរុប ធ្លាក់ចុះ ១០,៧% ធៀបត្រីមាសមុន មកត្រឹម ២៦៣៣,៥ពាន់លានរៀល ក្នុងនោះ ចំណូលចរន្ត ធ្លាក់ចុះ ៦,៤% មកត្រឹម ២៦២៣,៧ពាន់លានរៀល។ ចំណូលពន្ធ កើន ២,៥% ដល់ ២៤១៦,៨ពាន់លានរៀល ដោយរួមចំណែកបាន ៩១,៨% ក្នុងចំណូលរដ្ឋាភិបាលសរុប។ ចំណូលមិនមែនពន្ធ ធ្លាក់ចុះ ៥៣,៥% មកត្រឹម ២០៦,៩ពាន់លានរៀល។ នៅត្រីមាសដដែល ចំណាយសរុប ធ្លាក់ចុះ ៥៦,២% ធៀបត្រីមាសមុន មកត្រឹម ១៩៥៨,០ពាន់លានរៀល ដោយសារការថយចុះ ៦៦,៦% នៃចំណាយមូលធន និង ៥០,៥% នៃចំណាយចរន្ត។ ចំណាយមូលធន ធ្លាក់ចុះមកត្រឹម ៥២៩,៤ ពាន់លានរៀល ហើយចំណាយចរន្ត ធ្លាក់ចុះមកត្រឹម ១៤២៨,៧ ពាន់លានរៀល ដោយសារការធ្លាក់ចុះនៃចំណាយលើបៀវត្សរ៍ ឧបត្ថម្ភធននិងជំនួយសង្គម និង ចំណាយចរន្តផ្សេងទៀត។

## អតិផរណា និងអត្រាប្តូរប្រាក់

ក្នុងរយៈពេលមួយឆ្នាំរហូតដល់ត្រីមាសទី១ ឆ្នាំ២០១៥ ថ្លៃទំនិញសរុប កើន ១,០% ធៀបនឹងកំណើន ៤,៦% ក្នុងរយៈពេលមួយឆ្នាំរហូតដល់ត្រីមាសទី១ ឆ្នាំ២០១៤។ ថ្លៃស្បៀងអាហារ និងភេសជ្ជៈគ្មានជាតិស្រា កើន ៤,២% រីឯថ្លៃដឹកជញ្ជូន ធ្លាក់ចុះ ១០,៩%។ ប្រាក់រៀល ឡើងថ្លៃ ០,៦% ទល់នឹងប្រាក់ដុល្លារ, ០,២% ទល់នឹងប្រាក់បាតថៃ និង ០,៥% ទល់នឹងប្រាក់ដុងវៀតណាម ធៀបនឹងត្រីមាសមុន។ មាសឡើងថ្លៃ ៧,០% ធៀបនឹងត្រីមាសមុន ដល់ ១៥០.៩ដុល្លារ/ជី រីឯម៉ាស៊ូត និងសាំង ធ្លាក់ថ្លៃ ១២,០% និង ១៣,៦% រៀងគ្នា។

## ស្ថានភាពក្រីក្រ

នៅខែឧសភា ២០១៥ ចំណូលប្រចាំថ្ងៃពិតរបស់កម្មករសំណង់មានជំនាញ និងអ្នកស៊ីឈ្នួលធ្វើស្រែ បានធ្លាក់ចុះ បើធៀបនឹងខែឧសភា ២០១៤។ អង្កេតក្នុងខែឧសភានេះបង្ហាញថា ពលករ ៤ក្រុម រកប្រាក់ចំណូលបានតិចជាងកាលពី អង្កេតក្នុងខែកុម្ភៈ។

ប្រាក់ចំណូលប្រចាំថ្ងៃរបស់អ្នកធាក់ស៊ីក្លូ ធ្លាក់ចុះ ៣,៧% ធៀបនឹងអង្កេតលើកមុន មកត្រឹម ១២.៤២៧រៀល/ថ្ងៃ ដោយសារជាសំខាន់ អតិថិជនមានចំនួនតិចជាងមុន។ អ្នកឆ្លើយសម្ភាសន៍ទាំងអស់គ្នា សុទ្ធតែមកពីតាមខេត្តនៅក្បែររាជធានីភ្នំពេញ ជាពិសេសខេត្តព្រៃវែង (៥២%)។ អ្នកធាក់ស៊ីក្លូស្ទើរតែគ្រប់គ្នាជាអ្នករកចំណូលចម្បងក្នុងគ្រួសារ ហើយ ៧២% នៃអ្នកឆ្លើយសម្ភាសន៍ប្រាប់ថា ចំណូលរបស់ខ្លួនមិនគ្រប់គ្រាន់សម្រាប់ចិញ្ចឹមគ្រួសារទេ។ ចំណាយប្រចាំថ្ងៃរបស់អ្នកធាក់ស៊ីក្លូ ស្រូបអស់ ៧៨% នៃប្រាក់ចំណូលសរុបរបស់គាត់ ហើយភាគច្រើនទៅលើម្ហូបអាហារសម្រាប់ខ្លួនគាត់។ គ្រួសារអ្នកធាក់ស៊ីក្លូ ៦៨% ត្រូវស៊ីឈ្នួលធ្វើស្រែដើម្បីរកចំណូលបន្ថែម។

ប្រាក់ចំណូលរបស់អ្នកលីសែង ធ្លាក់ចុះ ៦,០% ធៀបអង្កេតលើកមុន មកត្រឹម ១៥.៧៨២រៀល/ថ្ងៃ ហើយពួកគេ ៨០% ប្រាប់ថា វាបណ្ដាលមកពីកង្វះការងារ និងកំណើនចំនួនអ្នកប្រកបរបរនេះ។ អ្នកលីសែង ៩២% ត្រូវជួលកន្លែងស្នាក់នៅក្នុងក្រុងភ្នំពេញ ដោយមានគ្នាជាមធ្យម ៦នាក់ក្នុងមួយកន្លែង។ ពួកគេចំណាយប្រាក់អស់ ១០០០រៀល/ថ្ងៃ លើថ្លៃឈ្នួលកន្លែងស្នាក់នៅ។ នៅក្នុងចំណាយសរុបប្រចាំថ្ងៃរបស់ពួកគេ ចំណាយលើស្បៀងអាហារមានចំណែក ៨៩%។

នៅខែឧសភា ចំណូលរបស់កម្មករសំណង់គ្មានជំនាញ ធ្លាក់ចុះ ៧,៣% មកត្រឹម ១៥.៤៥៣រៀល/ថ្ងៃ។ អ្នកឆ្លើយសម្ភាសន៍ ៧០% ប្រាប់ថា មានមនុស្សកាន់តែច្រើនមកចាប់យកការងារនេះ ប៉ុន្តែការងារមានតិចជាងមុន។ ជាមធ្យម កម្មករធ្វើការ ៨ម៉ោង/ថ្ងៃ។ ពួកគេ ៧៨% មករស់នៅរាជធានីភ្នំពេញតែម្នាក់ឯង ហើយប្រាក់ចំណូលរកបាន អាចទ្រទ្រង់ជីវភាពគ្រួសារបានតែមួយភាគប៉ុណ្ណោះ។

ប្រាក់ចំណូលរបស់កម្មករមានជំនាញ កើន ១៧% ដល់ ១៩.៩១៨រៀល/ថ្ងៃ។ កម្មករ ៥៥% មករស់នៅភ្នំពេញជាមួយគ្រួសារ។ ពួកគេភាគច្រើនស្នាក់នៅកន្លែងការដ្ឋាន។ ចំណូលរបស់ពួកគេមិនគ្រប់គ្រាន់សម្រាប់ទ្រទ្រង់គ្រួសារទេ ហេតុនេះសមាជិកគ្រួសារនៅឯស្រុក ត្រូវរកចំណូលបន្ថែមដោយចិញ្ចឹមសត្វ ឬស៊ីឈ្នួលធ្វើស្រែឲ្យគេ។

ប្រាក់ចំណូលរបស់អ្នកលក់បន្លែ កើន ២១% ធៀបនឹងខែកុម្ភៈ ដល់ ១៨.១៧១រៀល/ថ្ងៃ។ ពួកគេភាគច្រើនមកពីខេត្តកណ្ដាល (៣៣%)។ អ្នកលក់បន្លែ ៤៥% ធ្វើដំណើរទៅមកផ្ទះប្រចាំថ្ងៃ រីឯអ្នកផ្សេងទៀតបានជួលផ្ទះគេនៅ ឬស្នាក់នៅជាមួយសាច់ញាតិនៅភ្នំពេញ។ អ្នកឆ្លើយសម្ភាសន៍ ៧៥% ប្រាប់ថា ចំណូលរបស់ខ្លួន មិនគ្រប់គ្រាន់សម្រាប់ទ្រទ្រង់គ្រួសារ ឬពង្រីកអាជីវកម្មទេ ដោយមាន ៣៨% ត្រូវខ្ចីបុលគេដើម្បីធ្វើអាជីវកម្ម និងដោះស្រាយចំណាយទ្រទ្រង់ជីវភាព។

អ្នករើសអេតចាយ មានចំណូលកើនដល់ ១៤.១៦៩រៀល/ថ្ងៃ ឬអត្រាកំណើនប្រាក់ចំណូលខ្ពស់ជាងគេ គឺ ៣៣%។ អ្នករើសអេតចាយ ៧៨% មកភ្នំពេញជាមួយគ្រួសារ។ ពួកគេពឹងផ្អែកជាសំខាន់លើការងារនេះ ប៉ុន្តែ ៧៥% ប្រាប់ថា ប្រាក់ចំណូលរបស់ខ្លួនមិនគ្រប់គ្រាន់សម្រាប់ការចាយវាយទេ។ ហេតុនេះ អ្នករើសអេតចាយ ៧៥% ត្រូវខ្ចីប្រាក់គេដើម្បីដោះស្រាយចំណាយប្រចាំថ្ងៃ។

ប្រាក់ចំណូលពិតប្រចាំថ្ងៃរបស់កម្មករកាត់ដេរ កើន ១,១% ធៀបនឹងអង្កេតលើកមុន ដល់ ១៤.៨០៣រៀល។ ក្នុងចំណោមអ្នកឆ្លើយសម្ភាសន៍ ១២០នាក់ កម្រិតសិក្សាដែលខ្ពស់ជាងគេ គឺ ត្រឹមថ្នាក់ទី៣។ ម្យ៉ាងទៀត មានកម្មករតែ ២៩% ប៉ុណ្ណោះ ដែលបានចូលរៀនវគ្គបណ្ដុះបណ្ដាលមុនពេលចូលធ្វើការ។ ការងារចម្បងរបស់ពួកគេគឺ ដេរ និងប៉ាក់សាមញ្ញៗ។ ពួកគេធ្វើការ ៥៨ម៉ោង/សប្ដាហ៍ (៦ថ្ងៃ/សប្ដាហ៍) រួមទាំងការងារបន្ថែមម៉ោងផង។ កម្មករ ៤០% អាចសន្សំប្រាក់សម្រាប់អនុវត្តផែនការការងារទៅថ្ងៃអនាគតរបស់ខ្លួន រីឯអ្នកផ្សេងទៀតមិនអាចទ្រទ្រង់ជីវភាពគ្រួសារដែលពឹងផ្អែកជាចម្បងលើពួកគេឡើយ។

# តាមដានសេដ្ឋកិច្ច - សូចនាករ

## តារាង ១. គម្រោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០០៧-១៥*

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 Q1 | Q2 | Q3 | Q4 | 2015 Q1 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | |
| កសិកម្ម | 135.6 | 92 | 615.0 | 530.7 | 725 | 531.6 | 930.5 | 28.9 | 27.6 | 0.0 | 0.0 | 25.8 |
| ឧស្សាហកម្ម | 709.1 | 724.9 | 818.5 | 403.7 | 2860.1 | 829.3 | 3257 | 179.0 | 239.3 | 434.3 | 149.9 | 342.8 |
| *កាត់ដេរ* | 170.7 | 142.8 | 90.1 | 122.8 | 393.9 | 497 | 324.1 | 109.3 | 172.4 | 81.6 | 30.3 | 63.9 |
| សេវាកម្ម | 1742.5 | 10,003.2 | 4432.0 | 1337.3 | 3425.4 | 916.6 | 140.7 | 219.1 | 114.4 | 289.1 | 0.0 | 2504.6 |
| *សណ្ឋាគារ និងទេសចរណ៍* | 1048.3 | 8758.1 | 3980.1 | 1105.1 | 2850.9 | 691.5 | 106 | 163.3 | 15.4 | 268.1 | 0.0 | 60.6 |
| សរុប | 2587.2 | 10570.9 | 5865.5 | 2271.7 | 7010.42 | 2278.0 | 4328 | 426.9 | 302.2 | 625.8 | 149.9 | 2873.2 |
| | | | | | | | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | |
| សរុប | - | - | - | - | - | - | - | -75.8 | -29.2 | 64.1 | -76.0 | 1816.8 |
| | | | | | | | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | |
| សរុប | -32.0 | 308.6 | -44.5 | -61.3 | 209 | -67.5 | 90.1 | 95.1 | -81.8 | 142.7 | -91.5 | 573.0 |

* Including expansion project approvals. Source: Cambodian Investment Board

## តារាង ២. តម្លៃគម្រោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០៧-១៥

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 Q1 | Q2 | Q3 | Q4 | 2015 Q1 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | លានដុល្លារ | | | | | |
| ភូមិគ្រឹះ និងផ្ទះ | 376.3 | 376.2 | 213.9 | 220.1 | 405.1 | 547.3 | 658.9 | 133.6 | 84.0 | 33.1 | 20.4 | 122.3 |
| ផ្សេងៗ | 259.5 | 740.9 | 187.8 | 217.8 | 199.9 | 463.6 | 859.6 | 190.0 | 141.7 | 105.6 | 11.7 | 49.8 |
| សរុប | 635.8 | 1117.0 | 441.2 | 489.8 | 605.0 | 1010.9 | 1518.5 | 323.6 | 225.7 | 138.7 | 32.1 | 172.0 |
| | | | | | | | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | |
| សរុប | - | - | - | - | - | - | - | - | 30.3 | 38.5 | 76.9 | 435.8 |
| | | | | | | | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | |
| សរុប | 96.7 | 75.7 | -60.5 | 11.0 | 23.5 | 67.1 | 28.1 | -15.6 | 157.5 | 107.6 | -21.8 | -19.8 |

Source: Department of Cadastre and Geography of Phnom Penh municipality

## តារាង ៣. ចំនួនអ្នកដំណើរបរទេសមកដល់ប្រទេសកម្ពុជា ឆ្នាំ២០០៧-១៥

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 Q1 | Q2 | Q3 | Q4 | 2015 Q1 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | ចំនួនអ្នកដំណើរ (ពាន់នាក់) | | | | | |
| តាមផ្លូវអាកាស | 1280.2 | 1239.4 | 1111.7 | 1304.3 | 1480.4 | 1722.1 | 2017.7 | 699.0 | 438.2 | 497.5 | 638.8 | 725.1 |
| តាមផ្លូវគោក និងទឹក | 740.5 | 881.9 | 999.7 | 1094.6 | 1401.4 | 1862.2 | 2192.5 | 569.0 | 495.2 | 501.2 | 663.9 | 647.6 |
| សរុប | 2020.7 | 2121.3 | 2111.5 | 2398.9 | 2881.8 | 3584.3 | 4210.2 | 1268.0 | 933.4 | 998.7 | 1302.7 | 1372.6 |
| | | | | | | | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | |
| សរុប | - | - | - | - | - | - | | 10.0 | -26.4 | 7.0 | 30.4 | 5.4 |
| | | | | | | | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | |
| សរុប | 18.9 | 5.0 | -0.5 | 13.6 | 20.1 | 24.4 | 17.5 | 8.0 | 1.4 | 3.5 | 13.0 | 8.3 |

Source: Ministry of Tourism

## តារាង ៤. ការនាំចេញ និងនាំចូល ឆ្នាំ២០០៧-១៥*

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 Q1 | Q2 | Q3 | Q4 | 2015 Q1 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | លានដុល្លារ | | | | | |
| ការនាំចេញសរុប | 3050.3 | 3097.8 | 2901.6 | 3630.2 | 4929.5 | 6106.4 | 6982.4 | 1976.5 | 1859.8 | 2132.5 | 2137.1 | 2170.1 |
| ក្នុងនេះ៖ សម្លៀកបំពាក់ទៅ | 2938.9 | 2986.2 | 2565.3 | 3223.4 | 4259.6 | 5015.4 | 5386.1 | 1464.0 | 1379.2 | 1624.7 | 1492.6 | 1548.8 |
| - *សហរដ្ឋអាមេរិក* | 1956.5 | 1908.3 | 1512.6 | 1853.9 | 2055.3 | 2143.3 | 2075.2 | 531.1 | 452.5 | 511.2 | 468.8 | 491.08 |
| - *សហភាពអឺរ៉ុប* | 654.3 | 689.0 | 644.7 | 809.5 | 1322.2 | 1716.9 | 1969.6 | 532.7 | 558.5 | 673.8 | 638.7 | 617.3 |
| - *អាស៊ាន* | 3.2 | 10.8 | 6.9 | 9.9 | 17.6 | 39.4 | 60.2 | 21.9 | 19.3 | 20.5 | 21.7 | 24.8 |
| - *ជប៉ុន* | 28.5 | 25.2 | 44.5 | 86.5 | 147.0 | 188.6 | 278.7 | 101.4 | 74.9 | 117.6 | 89.2 | 121.4 |
| - *ប្រទេសផ្សេងៗ* | 296.4 | 352.9 | 356.5 | 463.6 | 717.5 | 927.2 | 1002.9 | 277.0 | 273.9 | 301.6 | 274.2 | 294.2 |
| កសិកម្ម | 55.7 | 44.5 | 73.1 | 164.9 | 362.1 | 376.7 | 554.5 | 167.0 | 157.3 | 133.7 | 166.4 | 150.3 |
| - *កៅស៊ូ* | 41.0 | 35.8 | 51.6 | 89.1 | 197.6 | 176.6 | 175.2 | 31.7 | 40.0 | 34.8 | 47.5 | 41.7 |
| - *ឈើ* | 8.7 | 3.4 | 3.5 | 34.1 | 48.8 | 36.8 | 73.6 | 55.9 | 48.4 | 19.6 | 8.2 | 13.9 |
| - *ត្រី* | 3.2 | 2.3 | 3.9 | 2.8 | 3.1 | 2.0 | 1.2 | 0.3 | 0.2 | 0.1 | 0.2 | 0.2 |
| - *អង្ករ* | 1.5 | 2.6 | 10.9 | 34.7 | 106.6 | 146.4 | 262.3 | 57.9 | 52.8 | 55.8 | 82.0 | 89.5 |
| - *ផលិតផលកសិកម្មផ្សេងៗ* | 1.2 | 0.5 | 3.0 | 4.1 | 6.0 | 14.9 | 42.4 | 21.2 | 16.0 | 23.5 | 28.5 | 5.2 |
| ផ្សេងៗ | 55.8 | 67.1 | 263.2 | 242.0 | 307.9 | 714.4 | 1088.2 | 345.5 | 323.3 | 373.0 | 478.2 | 471.0 |
| ការនាំចូលសរុប ក្នុងនេះ៖ | 3770 | 4272 | 4331.5 | 5190.6 | 6375.9 | 8593.3 | 8639.4 | 2238.2 | 2454.4 | 2794.8 | 2807.9 | 2717.3 |
| សាំង | 73.7 | 84.9 | 91.13 | 108.6 | 294.4 | 308.0 | 306.4 | 77.4 | 83.2 | 80.2 | 93.9 | 34.5 |
| ម៉ាស៊ីត | 133.7 | 119.5 | 180.67 | 203.8 | 447 | 559.5 | 569.1 | 148.5 | 142.5 | 163.4 | 147.9 | 45.1 |
| សម្ភារសំណង់ | 44.3 | 56.3 | 49.74 | 57.6 | 48.1 | 66.1 | 80.8 | 27.8 | 29.2 | 29.0 | 31.6 | 12.4 |
| ផ្សេងៗ | 3518.5 | 4011.8 | 4010 | 4820.6 | 5586.4 | 7659.1 | 7682.6 | 1984.5 | 2199.5 | 2522.2 | 2534 | 835.2 |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| ជញ្ជីងពាណិជ្ជកម្ម | -719.9 | -1174.7 | -1429.9 | -1560.5 | -1446.4 | -1341.6 | | -261.7 | -589.5 | -662.3 | -670.8 | -547.2 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | - | - | - | - | - | - | | 9.8 | -5.8 | 17.8 | -8.1 | 3.8 |
| ការនាំចេញសរុប | - | - | - | - | - | - | | 8.9 | -5.9 | 14.7 | 0.2 | 1.5 |
| ការនាំចូលសរុប | - | - | - | - | - | - | | 5.1 | 9.4 | 14.1 | 0.5 | -3.2 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | 8.9 | 1.6 | -14.1 | 25.7 | 32.1 | 17.7 | | 19.5 | 9.6 | 3.6 | 11.9 | 5.8 |
| ការនាំចេញសរុប | 8.5 | 1.6 | -6.3 | 25.1 | 35.8 | 23.9 | | 25.3 | 14.8 | 8.3 | 17.7 | 9.8 |
| ការនាំចូលសរុប | 23.7 | 13.3 | 1.4 | 19.8 | 22.8 | 16.8 | | 2.1 | 10.8 | 35.7 | 31.8 | 21.4 |

* Import data include tax-exempt imports.

Sources: Department of Trade Preference Systems, Ministry of Commerce and Customs and Excise Department, MEF (website)

## តារាង ៥. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានសាច់ប្រាក់ ឆ្នាំ២០០៧-១៥ (ពាន់លានរៀល)

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 Q1 | Q2 | Q3 | Q4 | 2015 Q1 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ចំណូលសរុប | 1146.1 | 5290.0 | 4885.2 | 5989.0 | 6251.4 | 7691.9 | 8255.2 | 2220.5 | 2793.7 | 2580.6 | 2948.6 | 2633.5 |
| ចំណូលចរន្ត | 1141.6 | 5210.7 | 4855.9 | 5859.1 | 6179.3 | 7443.8 | 8233.2 | 2219.2 | 2765.2 | 2571.4 | 2803.6 | 2623.7 |
| ចំណូលពន្ធ | 965.2 | 4409.9 | 4268.0 | 4693.0 | 5277.5 | 6334.8 | 7198.1 | 1988.7 | 2383.1 | 2264.6 | 2358.8 | 2416.8 |
| ពន្ធក្នុងស្រុក | 661.8 | 3248.4 | 3088.6 | 3533.6 | 4071.6 | 5002.8 | 5728.1 | 1593.6 | 1943.2 | 1798.0 | 1891.6 | 2002.8 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | 303.5 | 1161.5 | 1064.7 | 1159.4 | 1205.9 | 1331.7 | 1470.0 | 449.0 | 439.9 | 466.5 | 467.2 | 414.0 |
| ចំណូលមិនមែនពន្ធ | 176.4 | 800.8 | 702.1 | 1166.1 | 901.8 | 1118.2 | 1035.2 | 176.6 | 382.1 | 306.9 | 444.8 | 206.9 |
| ចំណូលលើទ្រព្យសម្បត្តិ | 13.6 | 78.0 | 64.6 | 291.1 | 63.8 | 143.0 | 84.0 | 11.1 | 40.8 | 21.2 | 15.4 | 3.0 |
| លក់ទំនិញ និងសេវា | 124.3 | 424.7 | 408.0 | 460.1 | 588.7 | 667.4 | 750.3 | 160.3 | 197.5 | 212.9 | 300.5 | 189.2 |
| ចំណូលមិនមែនពន្ធផ្សេងទៀត | 38.5 | 298.2 | 228.2 | 408.9 | 249.3 | 298.8 | 200.8 | 5.2 | 143.7 | 72.7 | 128.9 | 14.7 |
| ចំណូលជាមូលធន | 4.5 | 79.3 | 29.3 | 129.9 | 72.1 | 247.9 | 73.4 | 1.3 | 28.5 | 9.2 | 145.0 | 9.8 |
| ចំណាយសរុប | 1689.7 | 6297.8 | 7383.5 | 8784.6 | 9032.4 | 9660.9 | 12535.7 | 2618.8 | 2867.2 | 3349.0 | 4471.4 | 1958.1 |
| ចំណាយជាមូលធន | 807.4 | 2574.4 | 2694.9 | 2853.2 | 3546.9 | 3628.3 | 5567.5 | 1187.1 | 1395.9 | 1421.7 | 1586.0 | 529.4 |
| ចំណាយចរន្ត | 882.3 | 3809.0 | 4440.0 | 4773.1 | 5341.2 | 6188.4 | 6968.3 | 1431.7 | 1471.4 | 1927.3 | 2885.4 | 1428.7 |
| បៀវត្សរ៍ | 362.6 | 1397.0 | 2012.0 | 2048.8 | 2170.6 | 2486.6 | 2997.3 | 860.0 | 931.0 | 918.4 | 1046.1 | 935.1 |
| ឧបត្ថម្ភធន និងជំនួយសង្គមកិច្ច | 194.2 | 927.1 | 871.4 | 1099.4 | 1518.8 | 1586.8 | 1563.0 | 213.1 | 259.6 | 434.8 | 719.5 | 194.3 |
| ចំណាយចរន្តផ្សេងទៀត | 325.5 | 1384.9 | 1556.6 | 1624.8 | 1651.8 | 2115.1 | 2408.0 | 358.6 | 280.8 | 574.1 | 1119.9 | 299.3 |
| សមតុល្យជាទូទៅ | -543.6 | -1007.8 | -2498.3 | -2795.7 | -1271.4 | -1969.0 | -4280.6 | -398.4 | -73.5 | -768.5 | -522.8 | 675.5 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 741.5 | 2055.1 | 1746.1 | 1845.2 | -2781.0 | 2457.8 | 4326.2 | 977.9 | 1123.9 | 1,012.5 | 857.9 | 232.2 |
| ហិរញ្ញប្បទានក្នុងស្រុក | -185.8 | -127 | 474.9 | 938.6 | 2379.2 | -332.9 | 824.4 | -915.0 | -172.9 | -279.3 | -61.4 | -1,248.7 |

Source: Ministry of Economy and Finance website

## តារាង៦. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្តូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ២០០៧-១៥

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 Q1 | Q2 | Q3 | Q4 | 2015 Q1 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| (តុលា-ធ្នូ ២០០៦:១០០) | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ភ្នំពេញ - ទំនិញគ្រប់មុខ | 5.8 | 19.7 | -0.7 | 4.1 | 5.4 | 2.3 | 3.9 | 4.6 | 4.8 | 4.0 | 2.1 | 1.0 |
| - អាហារ និងភេសជ្ជៈគ្មានជាតិស្រា | 9.9 | 33.1 | -0.3 | 4.4 | 6.5 | 2.5 | 4.9 | 5.7 | 5.3 | 5.1 | 3.4 | 4.2 |
| - ដឹកជញ្ជូន | 5.8 | 19.4 | -10.7 | 7.0 | 6.9 | 3.3 | -1.0 | -1.1 | 0.5 | -0.2 | -3.3 | -10.9 |
| | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 4062.7 | 4058.2 | 4140.5 | 4187.1 | 4063.6 | 4039.2 | 4036.2 | 3993.8 | 4026.9 | 4059.5 | 4064.7 | 4042.2 |
| រៀលក្នុង ១ បាតថៃ | 122.8 | 123.5 | 121.1 | 133.1 | 133.2 | 130.0 | 124.9 | 123.0 | 124.8 | 127.1 | 124.6 | 124.4 |
| រៀលក្នុង ១០០ ដុងវៀតណាម | 25.0 | 24.8 | 23.4 | 21.7 | 19.7 | 19.4 | 19.1 | 19.1 | 19.2 | 19.2 | 19.1 | 19.0 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 83.2 | 105.9 | 113.1 | 147.5 | 184.5 | 200.9 | 152.3 | 156.6 | 155.9 | 155.5 | 141.1 | 150.9 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 3262.3 | 4555.2 | 3170.9 | 3859.3 | 4761.2 | 4941.2 | 4852.1 | 4971.2 | 5006.7 | 5047.6 | 4382.8 | 3823.4 |
| ថ្លៃសាំង (រៀល/លីត្រ) | 4005.0 | 4750.8 | 3593.1 | 4368.1 | 5044.5 | 5312.7 | 5083.3 | 5171.5 | 5200.0 | 5348.6 | 4613.0 | 3986.2 |

Sources: National Institute of Statistics, National Bank of Cambodia and CDRI

## តារាង៧. ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០០៧-១៥ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 Q1 | Q2 | Q3 | Q4 | 2015 Q1 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ពាន់លានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 10,735.0 | 10,345.0 | 14,655.0 | 16,697.9 | 17,893.9 | 18,154.5 | 21,260.1 | 23,344.4 | 26,235.8 | 26,817.8 | 26,699.7 | 26,823 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | 576.0 | 15,13.3 | 1573.0 | 2778.9 | 5760.8 | 10,437.4 | 11,508.3 | 11,817.4 | 12,024.4 | 13,950.5 | 15,859.8 | 16,863.2 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -1816.0 | -2987.0 | -2252.0 | -2126.6 | -2123.1 | -2486.4 | -2794.9 | -3349.3 | -3747.3 | -4113.0 | -4359.1 | -5064 |
| ឥណទានដល់ផ្នែកឯកជន | 6386.0 | 9894.0 | 10,532.0 | 13,331.2 | 17,552.8 | 23,536.6 | 27,608.8 | 28,584.5 | 30,621.3 | 33,226.4 | 36,244.6 | 37,759.4 |
| រូបិយវត្ថុទូទៅ M2 | 11,311.0 | 11,858.0 | 16,228.0 | 19,476.8 | 23,654.7 | 28,591.9 | 32,768.4 | 35,161.8 | 38,259.9 | 40,768.3 | 42,559.5 | 43,685.2 |
| រូបិយវត្ថុ M1 | 2052.0 | 2399.0 | 3120.0 | 3220.9 | 3956.2 | 4045.7 | 4878.2 | 5376.2 | 5231.3 | 5583.1 | 6308.4 | 6628.0 |
| រូបិយវត្ថុផ្សេងៗ | 9259.0 | 9459.0 | 13,108.0 | 16,255.9 | 19,698.5 | 24,546.2 | 27,890.2 | 29,785.7 | 33,028.5 | 35,185.2 | 36,251.1 | 37,058.2 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ M2 | 62.9 | 4.8 | 36.9 | 20.0 | 17.8 | 20.9 | 14.6 | 15.4 | 20.8 | 38.9 | 29.9 | 24.2 |
| រូបិយវត្ថុ M1 | 23.8 | 16.9 | 30.1 | 3.2 | 16.9 | 2.3 | 20.6 | 19.5 | 14.1 | 18.3 | 29.3 | 23.3 |
| រូបិយវត្ថុផ្សេងៗ | 75.2 | 2.2 | 38.6 | 24.0 | 17.9 | 44.6 | 13.6 | 14.6 | 22.0 | 42.8 | 30.0 | 24.4 |

Source: National Bank of Cambodia

តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បម្រែបម្រួលជាភាគរយធៀបឆ្នាំមុន | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2011 | 2012 | 2013 | 2014 | | | | 2015 | | 2014 | 2015 | |
| | | | | កុម្ភៈ | ឧសភា | សីហា | វិច្ឆិកា | កុម្ភៈ | ឧសភា | វិច្ឆិកា | កុម្ភៈ | ឧសភា |
| អ្នកធាក់ស៊ីក្លូ | 9532 | 10,303 | 10,438 | 10,832 | 10,764 | 9867 | 11,634 | 12,950 | 12,467 | 7.8 | 19.6 | 26.4 |
| អ្នកលីសែង | 10,785 | 12,143 | 13,247 | 12,141 | 12,568 | 13,399 | 16,188 | 16,798 | 15,782 | 22.2 | 38.4 | 17.8 |
| អ្នកលក់បន្លែតូចតាច | 8337 | 10,771 | 11,366 | 12,294 | 13,581 | 15,372 | 17,735 | 15,007 | 18,171 | 43.1 | 22.1 | 22.1 |
| អ្នករើសអេតចាយ | 8388 | 8680 | 9819 | 9593 | 9214 | 8337 | 9548 | 10,627 | 14,169 | -1.4 | 10.8 | 10.8 |
| អ្នកបម្រើភោជនីយដ្ឋាន* | 5986 | 6111 | 6697 | 7449 | 6696 | 7565 | 9435 | 8,466 | 8,742 | 40.0 | 13.7 | 15.6 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 5695 | 6151 | 6599 | 8932 | 5836 | 8795 | 6781 | 8,303 | 8,063 | 6.6 | -7.0 | -8.3 |
| កម្មកររោងចក្រកាត់ដេរ | 8409 | 8932 | 10,161 | 9548 | 11,412 | 11,388 | 12,092 | 14,644 | 14,803 | 16.3 | 53.4 | 29.7 |
| អ្នករត់ម៉ូតូឌុប | 11,568 | 12,930 | 13,450 | 13,227 | 13,401 | 12,656 | 14,259 | 14,549 | 14,692 | 8.6 | 10 | 16.1 |
| កម្មករសំណង់គ្មានជំនាញ | 10,307 | 11,078 | 13,184 | 15,162 | 15,316 | 15,401 | 15,436 | 16,678 | 15,453 | 15.4 | 10 | 0.3 |
| កម្មករសំណង់មានជំនាញ | 13,159 | 13,743 | 15,442 | 15,163 | 15,765 | 20,420 | 18,302 | 17,050 | 19,918 | 10.4 | 12.4 | -2.5 |

* Waitresses' earnings do not include meals and accommodation provided by shop owners. Surveys on the incomes of waitresses, rice-field workers, garment workers, motorcycle taxi drivers and construction workers began in February 2000.
Source: CDRI

*តពីទំព័រ ២០* **ព័ត៌មានថ្មីៗ...**

ព្រឹត្តិការណ៍នេះបានប្រារព្ធឡើង នៅថ្ងៃទី ២៦ មិថុនា ដើម្បីឲ្យបានស្របពេលគ្នាជាមួយទស្សនកិច្ចនៃ គណៈប្រតិភូជាន់ខ្ពស់នៃ CPAPD ដឹកនាំដោយ ឯកឧត្តម Han Qide អនុប្រធានគណៈកម្មាធិការជាតិ នៃសន្និសីទពិគ្រោះយោបល់ ផ្នែកនយោបាយ នៃសាធារណរដ្ឋប្រជាមានិតចិន និង ប្រធាននៃ CPAPD។ សុន្ទរកថាគន្លឹះត្រូវបានធ្វើឡើងដោយ ឯកឧត្តម Han Qide និង ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី។

កិច្ចសន្ទនា ដែលមានការចូលរួមតាមការអញ្ជើញពីសំណាក់អ្នកតំណាងជាន់ខ្ពស់ប្រហែល ១០០នាក់ មកពី សហគមន៍ស្រាវជ្រាវផ្នែកគោលនយោបាយ វិស័យអប់រំ វិស័យឯកជន សមាគមយុវជន និងអង្គការមិនមែនរដ្ឋាភិបាលដទៃទៀត បានផ្ដល់ជាវេទិកាដ៏វិសេសសម្រាប់ការពិភាក្សាពី ឱកាស និងបញ្ហាប្រឈម ផុសចេញពីការពង្រីកពង្រឹងភាពជាដៃគូរបស់កម្ពុជាជាមួយប្រទេសចិន ទាំងជាលក្ខណៈទ្វេភាគី និងលក្ខណៈតំបន់ និងពីបែបបទដែលប្រទេសទាំងពីរអាចធ្វើការរួមគ្នា ដើម្បីបានផលប្រយោជន៍ទៅវិញទៅមក។

CDRI ក្នុងតួនាទីជាអ្នកសម្របសម្រួលនៃវេទិកាស្រាវជ្រាវអភិវឌ្ឍន៍ (DRF) នៃកម្ពុជា និងក្នុងនាម ក្រុមចំណាប់អារម្មណ៍ស្រាវជ្រាវ DRF អំពីកម្ពុជា និងតំបន់ជុំវិញ បានរៀបចំនូវកិច្ចប្រជុំតុមូលគោលនយោបាយមួយ ស្ដីពី "ការរៀបចំការអប់រំកម្រិតឧត្ដមសិក្សានៅកម្ពុជា សម្រាប់សហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ ២០១៥ និងតទៅអនាគត"។ អ្នកតំណាងប្រហែល ៤០នាក់មកពីមជ្ឈដ្ឋានសិក្សាអប់រំ ក្រសួងអប់រំយុវជននិងកីឡា ក្រសួងសុខាភិបាល និង អង្គការមិនមែនរដ្ឋាភិបាលខាងវិស័យអប់រំនៅកម្ពុជា បានចូលរួមក្នុងកិច្ចប្រជុំតុមូល នៅថ្ងៃទី ៥ មិថុនា នេះ ដើម្បីពិភាក្សាពី បញ្ហាប្រឈម និងឱកាសល្អសម្រាប់ឧត្ដមសិក្សានៅកម្ពុជា នៅក្នុងបរិបទនៃការធ្វើសមាហរណកម្មអាស៊ាន។

## ការស្រាវជ្រាវ

### ផ្នែកកសិកម្ម

ក្រុមអ្នកស្រាវជ្រាវកំពុងអនុវត្តគម្រោងសិក្សាចំនួន ៩ ក្នុងនោះមាន ១គម្រោង ត្រូវអនុវត្តរួមគ្នា ជាមួយក្រុមស្រាវជ្រាវផ្នែកសុខាភិបាល។ គម្រោងចំនួន ៣ ទទួលបានការទ្រទ្រង់ផ្នែកហិរញ្ញវត្ថុពីទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសស៊ុយអែត (Sida)។ របាយការណ៍សម្រាប់គម្រោងទី១ ស្ដីពីផលប៉ះពាល់នៃការធ្វើកសិកម្មតាមកិច្ចសន្យា ទៅលើជីវភាពរបស់ម្ចាស់ដីតូចៗ បានចងក្រងរួចរាល់សម្រាប់បោះពុម្ពផ្សាយជាឯកសារពិភាក្សា។ របាយការណ៍ព្រាងដំបូងសម្រាប់គម្រោងការសិក្សាពីយន្តកម្មនៅតាមកសិដ្ឋាន និងនិន្នាការទីផ្សារពលកម្មកសិកម្ម កំពុងរង់ចាំយោបល់ត្រឡប់ពីអ្នកស្រាវជ្រាវក្នុងវិស័យដូចគ្នាដែលជួយពិនិត្យ។ សម្រាប់គម្រោងទី៣ ស្ដីពីផលប៉ះពាល់នៃគោលនយោបាយជំរុញការនាំចេញអង្ករ និងសន្តិសុខស្បៀង ខាងក្រុមស្រាវជ្រាវកំពុងចងក្រងរបាយការណ៍។

របាយការណ៍ព្រាងដំបូងសម្រាប់ការសិក្សាស្ដីពី ការវិភាគពីខ្សែចង្វាក់តម្លៃបន្ថែម និងផលិតកម្មសត្វចិញ្ចឹម នៅក្នុងដំណាក់កាលទី២ នៃគម្រោង គោលនយោបាយកសិកម្មសម្រាប់ប្រព័ន្ធដាំដុះផ្អែកលើដំណាំស្រូវនៅតំបន់មេគង្គកណ្ដាលដែលទទួលបានជំនួយទ្រទ្រង់ពី មជ្ឈមណ្ឌលអូស្ត្រាលីសម្រាប់ការស្រាវជ្រាវកសិកម្មអន្តរជាតិ (ACIAR) កំពុងចងក្រងបង្ហើយ។ នៅខែមិថុនាក្រុមស្រាវជ្រាវបានចាប់ផ្ដើមអនុវត្តគម្រោងថ្មីមួយស្ដីពីផលប៉ះពាល់នៃចំណាយសាធារណៈផ្នែកអប់រំ ទៅលើមូលធនមនុស្ស ភាពក្រីក្រ និងវិសមភាព៖ វិធីសាស្ត្រ CGE សម្រាប់កម្ពុជា។ ក្រុមស្រាវជ្រាវបានទទួលកិច្ចសន្យាមួយទៀត ដើម្បីអនុវត្តគម្រោងស្ដីពី ការវិភាគពីគោលនយោបាយស្រូវ៖ ផលពាក់ព័ន្ធនៃគោលនយោបាយនាំចេញអង្កររបស់វៀតណាម សម្រាប់កម្ពុជា ដែលទទួលបានជំនួយទ្រទ្រង់ផ្នែកហិរញ្ញវត្ថុពី ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) តាមរយៈ គំនិតផ្ដួចផ្ដើមគោលនយោបាយសាធារណៈទន្លេមេគង្គក្រោម (LMPPI)។ ការស្រាវជ្រាវនេះគ្រោងចាប់ផ្ដើមនៅខែសីហា ២០១៥។ កិច្ចសន្យាសម្រាប់គម្រោងរយៈពេល ៤ឆ្នាំ (២០១៥-១៨) ស្ដីពី ការសាកល្បងគំរូបែបថ្មីនៃការផ្សព្វផ្សាយបច្ចេកទេសកសិកម្មនៅក្នុងគម្រោង PADEE កម្ពុជា (គម្រោងអភិវឌ្ឍន៍កសិកម្ម និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា) ដែលទទួលបានមូលនិធិពី វិទ្យាស្ថានស្រាវជ្រាវពី គោលនយោបាយស្បៀងអាហារអន្តរជាតិ (IFPRI) កំពុងរៀបចំឡើង ហើយសកម្មភាពស្រាវជ្រាវគ្រោងចាប់ផ្ដើមនៅចុងខែសីហា ឬដើមខែកញ្ញា។

## ផ្នែកសេដ្ឋកិច្ច

នៅក្រោមកម្មវិធីរយៈពេល ៣ឆ្នាំនៃ បណ្ដាញមហាអនុតំបន់មេគង្គ (GMSNet) ស្ដីពី ការលើកកម្ពស់អនាគតការងារសម្រាប់យុវជន៖ ទីផ្សារពលកម្ម ការអភិវឌ្ឍជំនាញ និងវិស័យឯកជន ក្នុងមហាអនុតំបន់មេគង្គ ដែលទទួលបានមូលនិធិពី មជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍អន្តរជាតិ (IDRC) នៃប្រទេសកាណាដា វិទ្យាស្ថាន CDRI បានចាប់ប្រកាសឲ្យធ្វើការស្រាវជ្រាវជាលក្ខណៈប្រកួតប្រជែងលើកដំបូងបំផុតនៅក្នុងតំបន់ ដោយអ្នកចូលរួមប្រកួតត្រូវបញ្ជូនសំណើអនុគម្រោងរបស់ខ្លួនឲ្យបានត្រឹមថ្ងៃទី១៥ សីហា ២០១៥។ រហូតដល់ ១២អនុគម្រោង ក្នុងការស្រាវជ្រាវពីរផ្នែក គឺគោលនយោបាយ និងសកម្មភាព នឹងត្រូវបានជ្រើសរើសដើម្បីទទួលមូលនិធិសម្រាប់ការសិក្សា។

ការប្រជុំពិគ្រោះយោបល់មួយ បានប្រារព្ធឡើងនៅថ្ងៃទី១១ មិថុនា នៅរាជធានីភ្នំពេញ ដោយមានការអញ្ជើញចូលរួមពីសំណាក់អ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីពិភាក្សាលើលទ្ធផលស្រាវជ្រាវបឋមនៃគម្រោងស្ដីពី ទំនាក់ទំនងរវាងគោលនយោបាយសាធារណៈរបស់ប្រទេសជាដៃគូ ចំណាកស្រុក នឹងការអភិវឌ្ឍៈករណីសិក្សា និងអនុសាសន៍គោលនយោបាយ ដែលទទួលមូលនិធិពី អង្គការដើម្បីសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ (OECD)។កិច្ចសន្ទនាយ៉ាងផុសផុលក្នុងកិច្ចប្រជុំនោះបានផ្ដល់នូវការបកស្រាយ និងទស្សនៈផ្សេងៗជាច្រើន។ នាបច្ចុប្បន្ន ក្រុមស្រាវជ្រាវកំពុងចងក្រងរបាយការណ៍។

សមាសភាគពីរចុងក្រោយ(គោលនយោបាយទីផ្សារពលកម្ម និងទីផ្សារឥណទាន) នៃគម្រោងស្រាវជ្រាវរយៈពេល ៥ឆ្នាំ ស្ដីពីកំណើនសម្រាប់គ្រប់គ្នា ដែលទទួលបានជំនួយទ្រទ្រង់ពី Sida កំពុងដំណើរការទៅមុខ។ គម្រោង ចម្លើយតបរបស់សហគមន៍ទៅនឹងអំពើហិង្សាលើស្ត្រី បានចប់សព្វគ្រប់ ហើយក្រុមស្រាវជ្រាវកំពុងចាប់អនុវត្តការសិក្សាពីរថ្មីទៀត។គម្រោងទី១ ស្ដីពី ការពិនិត្យឡើងវិញលើការងារមិនទាន់ចប់៖ កត្តាកំណត់នានានៃលទ្ធភាពទទួលបានឥណទាន និងផលប៉ះពាល់លើផលិតកម្មកសិកម្ម និងការប្រើប្រាស់ដីនៅតំបន់ជនបទកម្ពុជា កំពុងដំណើរការដោយបានទទួលជំនួយឧបត្ថម្ភពី អង្គការភាពជាដៃគូសម្រាប់គោលនយោបាយសេដ្ឋកិច្ច (PEP)។ គម្រោងទី២ ស្ដីពី ការស្រាវជ្រាវពីផលប៉ះពាល់នៃចំណាកស្រុក និងប្រាក់ផ្ញើមកផ្ទះ ទៅលើគ្រួសារមានស្ត្រីជាមេគ្រួ បានទទួលការគាំទ្រពី GVC (ក្រុមស្ម័គ្រចិត្តស៊ីវិល) ហើយវានឹងជួយរួមចំណែកដល់គម្រោងសិក្សាថ្មីក្នុងផ្នែកសេដ្ឋកិច្ចស្ដីពី MIGRA SAFE ។

ក្រុមស្រាវជ្រាវផ្នែកសេដ្ឋកិច្ច មានមោទនភាព និងសេចក្ដីរីករាយក្នុងការស្វាគមន៍ការវិលត្រឡប់មកវិញនៃ អ្នកស្រាវជ្រាវពីររូប បន្ទាប់ពីបានបញ្ចប់ការសិក្សាថ្នាក់ក្រោយឧត្តម។ លោកស្រី ស្រ៊ុ បុប្ផារ័ត្ន បានបញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកសេដ្ឋកិច្ច ពីមហាវិទ្យាល័យមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម នៃសាកលវិទ្យាល័យ Tsukuba ប្រទេសជប៉ុន។ លោកស្រី អ៊ូច ច័ន្ទដារ៉ានី បានបញ្ចប់ថ្នាក់បណ្ឌិត ពីមហាវិទ្យាល័យសេដ្ឋកិច្ច នៃសាកលវិទ្យាល័យ Monash ប្រទេសអូស្ត្រាលី។

## ផ្នែកអប់រំ

ប្រធានផ្នែកអប់រំ និងអ្នកគ្រប់គ្រងជាន់ខ្ពស់នានា បានជួបប្រជុំជាមួយដៃគូអភិវឌ្ឍន៍មួយចំនួន ដូចជា Sida និងទីភ្នាក់ងារស្វីសសម្រាប់កិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍ (SDC) ដើម្បីពិភាក្សាលើគោលគំនិតស្ដីពី "ការស្រាវជ្រាវ កិច្ចសន្ទនាផ្នែកគោលនយោបាយ និងកម្មវិធីកសាងសមត្ថភាព សម្រាប់កំណែទម្រង់វិស័យអប់រំនៅកម្ពុជាឆ្នាំ២០១៤-១៨"។ ជាលទ្ធផល កិច្ចព្រមព្រៀងលើគម្រោងបំផុសគំនិតមួយមានរយៈពេល ៦ខែ ផ្ដល់មូលនិធិដោយ SDC ត្រូវបានចុះហត្ថលេខាកាលពីខែមេសា ដើម្បីបង្កើតឯកសារការងារចម្បងមួយសម្រាប់ កម្មវិធីកិច្ចសន្ទនា និងការស្រាវជ្រាវគោលនយោបាយស្ដីពី ការអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ (TVET) រយៈពេលវែង។ Sida បានប្ដេជ្ញាចិត្តគាំទ្រសំណើសុំរបស់ CDRI ដើម្បីធ្វើជាដៃគូជួយទ្រទ្រង់ផ្នែកធនធានសម្រាប់ "ការស្រាវជ្រាវពីគោលនយោបាយអប់រំថ្នាក់ឧត្តមសិក្សា និងការអភិវឌ្ឍសមត្ថភាពក្នុងឆ្នាំ២០១៥-១៦"។

មជ្ឈមណ្ឌលសិក្សាកម្រិតឧត្តមមួយ (HLH) ត្រូវបានបង្កើតឡើងនៅដើមឆ្នាំ២០១៥ ដើម្បីដើរតួជាចំណុចស្នូលសម្រាប់ឲ្យថ្នាក់ដឹកនាំក្នុងផ្នែកសិក្សាអប់រំកម្រិតឧត្តម បង្កើនកិច្ចសន្ទនា និងការជជែកវែកញែក ជំរុញការស្រាវជ្រាវនិងបណ្ដុះបណ្ដាល និង ផ្ដល់នូវគោលគំនិតបែបថ្មី និងរបៀបអនុវត្តល្អៗ ក្នុងបំណងជួយឲ្យសាកលវិទ្យាល័យ អាចបំពេញតួនាទីផ្នែកសង្គម និងការសិក្សាស្រាវជ្រាវរបស់ខ្លួន។ ព្រឹត្តិការណ៍ពីរដំបូងគេ បានប្រារព្ធឡើងក្នុងខែឧសភា ដោយមានបញ្ចូលនូវ កម្មវិធីបណ្ដុះបណ្ដាលមួយសម្រាប់ក្រុមសាស្ត្រាចារ្យនៃមហាវិទ្យាល័យវិទ្យាសាស្ត្រ ស្ដីពីការរៀនសូត្រតាមវិធីចម្រុះ (Blended Learning) និងការដកឃ្លាដើម្បីប្រជុំពិភាក្សាជាមួយថ្នាក់ដឹកនាំស្ថាប័នសិក្សាស្រាវជ្រាវនានាលើបញ្ហា "សាកលវិទ្យាល័យដើម្បីអ្វី ?"។

នៅខែមេសា ក្រុមស្រាវជ្រាវបានចាប់ផ្ដើមការងារលើគម្រោងដែលទទួលបានកិច្ចព្រមព្រៀងឲ្យអនុវត្តពី កម្មវិធីអភិវឌ្ឍន៍ជំនាញរបស់ SDC ដោយបានធ្វើអង្កេតមូលដ្ឋានមួយដើម្បីវាយតម្លៃពីតម្រូវការបណ្ដុះបណ្ដាល នៅក្នុងខេត្ត ក្រចេះ ស្ទឹងត្រែង និង ព្រះវិហារ។ ការប្រមូលទិន្នន័យអនុវត្តបានរួចរាល់ក្នុងខែមិថុនា ហើយការចងក្រងរបាយការណ៍រំពឹងថានឹងចប់សព្វគ្រប់ នៅត្រឹមពាក់កណ្ដាលខែសីហា។

## ផ្នែកបរិស្ថាន

អត្ថបទ ២ សម្រាប់គម្រោង ប្រទេសចិនឈានឡើងកម្រិតសាកល ដែលចងក្រងរួមគ្នាដោយក្រុមស្រាវជ្រាវផ្នែកបរិស្ថាន បានទទួលការយល់ព្រមសម្រាប់ការបោះពុម្ពផ្សាយ ក្នុងអត្ថបទសារព័ត៌មានអន្តរជាតិមួយចំនួន រីឯ អត្ថបទទី៣ កំពុងត្រួតពិនិត្យឡើងវិញ និងកែលំអ។ ក្រុមស្រាវជ្រាវនឹងរៀបចំសិក្ខាសាលាកម្រិតតំបន់មួយនៅរាជធានីភ្នំពេញ នៅថ្ងៃទី២២ កញ្ញា និង សិក្ខាសាលាកម្រិតឃុំមួយនៅខេត្តកំពត នៅដើមខែតុលា ដើម្បីផ្សព្វផ្សាយពីលទ្ធផលនៃការសិក្សា។

ការអនុវត្តនូវ ការវាយតម្លៃផ្នែកធារាសាស្ត្រ អភិបាលកិច្ចទឹក ការកសាងសមត្ថភាព និងការចែករំលែកចំណេះដឹង កំពុងបន្តទៅ

មុខនៅក្រោមគម្រោង ការប្រែប្រួលអាកាសធាតុ និងអភិបាលកិច្ចទឹកនៅកម្ពុជា ដែលទទួលបានមូលនិធិពី IDRC។ ក្រុមស្រាវជ្រាវបានរៀបចំសិក្ខាសាលាកម្រិតឃុំចំនួន ៣ និងផ្ដល់នូវ ការបណ្ដុះបណ្ដាល ៤វគ្គ ស្ដីពី ការធ្វើផែនការបន្សាំនៅសហគមន៍។ របាយការណ៍ចំនួន ៦ បានចងក្រងចប់សព្វគ្រប់ បន្ទាប់ពីបានកែសម្រួលឡើងវិញ នៅពេលទទួលបានយោបល់ត្រឡប់ពីអ្នកស្រាវជ្រាវក្នុងវិស័យស្រដៀងគ្នា។ របាយការណ៍នៃការសិក្សា នឹងបោះពុម្ពផ្សាយនៅក្នុងឆ្នាំនេះ ជា ឯកសារពិភាក្សា។

ក្រុមស្រាវជ្រាវផ្នែកបរិស្ថាន ទទួលបានអំណោយមូលនិធិពីគំនិតផ្ដួចផ្ដើមគោលនយោបាយសាធារណៈមេគង្គក្រោម របស់ USAIDសម្រាប់អនុវត្តគម្រោងស្រាវជ្រាវស្ដីពីចីរភាពនៃការអភិវឌ្ឍថាមពលវារីអគ្គិសនីនៅទន្លេមេគង្គ និងដៃទន្លេមេគង្គនៅកម្ពុជា។ ក្រុមស្រាវជ្រាវកំពុងកសាងវិធីសាស្ត្រ និងឧបករណ៍ស្រាវជ្រាវ ដូចជា កម្រងសំណួរសម្រាប់អង្កេត និងសេចក្ដីណែនាំសម្រាប់ការពិភាក្សាតាមក្រុមស្នូល។ សំណើមួយទៀតសម្រាប់ការវាយតម្លៃចុងក្រោយលើការអនុវត្តគម្រោងមួយ ស្ដីពី ការលើកកម្ពស់ជីវភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ សម្រាប់កសិករខ្នាតតូចនៅតំបន់ដីស្ងួតងាយរងគ្រោះជាងគេក្នុងខេត្តសៀមរាប និងកំពង់ចាម បានទទួលការយល់ព្រម និងកិច្ចសន្យាឲ្យអនុវត្តពីសំណាក់អង្គការភ្លែនអន្តរជាតិ។

សំណើស្រាវជ្រាវសម្រាប់គម្រោងជាច្រើន បានបញ្ជូនទៅឲ្យដៃគូនានា។ សំណើថ្មីមួយស្ដីពី "ការសិក្សាសាកល្បងអំពីអភិបាលកិច្ចទឹក ក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុនៅកម្ពុជា" កំពុងរៀបរៀងឡើង ហើយអត្ថបទគោលគំនិតសម្រាប់អនុវត្ត "ការស្រាវជ្រាវស្ដីពីគោលនយោបាយប្រព័ន្ធស្បៀង និងការផ្សព្វផ្សាយបែបថ្មីនៅក្នុងទីផ្សារដើម្បីបង្ការជំងឺមិនឆ្លងគ្នា" បានបញ្ជូនទៅឲ្យ IDRC ពិនិត្យជ្រើសរើសរួចហើយ។

## ផ្នែកអភិបាលកិច្ច

ការសិក្សាស្ដីពីគណនេយ្យភាពសង្គមនៅកម្ពុជា និងកត្តាកំណត់ផ្អែកលើសិទ្ធិ បានបោះពុម្ពផ្សាយជា ឯកសារពិភាក្សារួចរាល់។ គម្រោងស្រាវជ្រាវ ២ កំពុងដំណើរការ។ ការសិក្សាស្ដីពីការផ្ដល់សេវាសាធារណៈនៅកម្ពុជា កំពុងរៀបចំឡើងវិញ ដើម្បីបំបែរចំណុចផ្ដោតទៅលើ សមត្ថភាពសម្រាប់ធ្វើកំណែទម្រង់វិសហមជ្ឈការនៅកម្ពុជា។ ការសិក្សាចំពេលវេលាល្អនេះព្យាយាមពិនិត្យថា តើមន្ត្រីរដ្ឋាភិបាលកំពុងប្រើប្រាស់យ៉ាងណានូវគោលគំនិតជាប់ទាក់ទងគ្នានៃ "កង្វះសមត្ថភាព" និង "ការកសាងសមត្ថភាព" នៅក្នុងបរិបទនៃកំណែទម្រង់វិសហមជ្ឈការ និងតើមន្ត្រីរដ្ឋាភិបាលសំដៅលើទិដ្ឋភាពនយោបាយបែបណា នៅពេលប្រើប្រាស់គោលគំនិតទាំងនេះនៅក្នុងការពិភាក្សាពីបញ្ហាប្រឈម និងឱកាសសម្រាប់ធ្វើកំណែទម្រង់។ ទោះបីមានឆន្ទៈនយោបាយរឹងមាំនៅកម្រិតខ្ពស់បំផុត ក្នុងការជំរុញកំណែទម្រង់វិសហមជ្ឈការទៅមុខក្ដី ក៏ដំណើរការនេះនៅយឺតយ៉ាវខ្លាំងណាស់ ដោយក្រសួងនានាតែងលើកហេតុផលពី "កង្វះសមត្ថភាព" នៅថ្នាក់ក្រោមជាតិ។ ការសិក្សាទី២ ស្ដីពី លទ្ធភាពសម្រាប់ធ្វើកិច្ចសន្ទនាអំពីអភិបាលកិច្ចទឹកទន្លេមេគង្គ ដែលជាសមាសភាគមួយនៃកម្មវិធីស្រាវជ្រាវពី ទឹក ដី និងប្រព័ន្ធអេកូឡូស៊ី គឺសំដៅពង្រឹងសមត្ថភាពប្រជាជនមូលដ្ឋាន ជាពិសេសស្ត្រីភេទ ក្នុងការចូលរួមផ្ដល់មតិលើការសម្រេចចិត្តកសាងទំនប់ដែលត្រូវប៉ះពាល់ដល់ដីធ្លី និងជីវភាពរបស់គាត់។ គម្រោងនេះបានជឿនលឿនទៅមុខល្អ ហើយខ្លឹមសារនៃឯកសារពិភាក្សាព្រាងដំបូង នឹងយកទៅចែករំលែកនៅក្នុងវេទិកាស្ដីពីទឹក នៅខែតុលា ២០១៥។

ក្រុមស្រាវជ្រាវ បានស្វាគមន៍ការវិលត្រឡប់មកវិញរបស់លោកស្រី លី តឹម បន្ទាប់ពីបានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតនៅប្រទេសញូហ្ស៊ីលែន។ លោកស្រី លី តឹម នឹងបន្តការងារលើការសិក្សាស្រាវជ្រាវទាក់ទងនឹងការជំរុញការចូលរួមរបស់ស្ត្រី ក្នុងដំណើរការសម្រេចចិត្តនៅកម្រិតមូលដ្ឋាន។

## ផ្នែកសុខភាព

ក្រុមស្រាវជ្រាវផ្នែកសុខភាព បានបន្តការងាររបស់ខ្លួនផ្នែកការអភិវឌ្ឍសង្គម ដោយផ្ដោតលើប្រព័ន្ធថែទាំសុខភាពសាធារណៈនៅកម្ពុជា អាហារូបត្ថម្ភ អនាម័យ យេនឌ័រ និង ពលកម្មកុមារ។ ក្រុមសិក្សាគម្រោង ការស្រាវជ្រាវដើម្បីកសាងប្រព័ន្ធសុខាភិបាលអំណោយផលដល់ជនក្រីក្រ ក្នុងពេលកសាងប្រទេសឡើងវិញបន្ទាប់ពីបានបញ្ចប់ទំនាស់ (ReBUILD) ដែលទទួលបានមូលនិធិពី DFID នោះ កំពុងចងក្រងឯកសារបោះពុម្ពផ្សាយ ២ គឺ៖ ចំណាយមហន្តរាយ និងភាពក្រីក្រនៅកម្ពុជា៖ ភស្តុតាងបានពីអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ឆ្នាំ២០០៤ ២០០៧ ២០០៩ ២០១០ និង ២០១១ និងការធ្វើកិច្ចសន្យាផ្ដល់សេវាសុខភាពសាធារណៈ៖ ការយល់ដឹងទទួលបានពីបុគ្គលិកសុខាភិបាល។ គម្រោងផ្នែកសុខភាពមួយទៀតស្ដីពី ការបញ្ជូនស្ត្រីត្រូវសម្រាលកូនក្នុងប្រព័ន្ធសុខាភិបាលនៅកម្ពុជាដែលជាគម្រោងរួមគ្នាជាមួយ មជ្ឈមណ្ឌលនូហ្វៀលសម្រាប់ការអភិវឌ្ឍ និងសុខភាពអន្តរជាតិ (Nuffield Centre for International Health and Development) និងសាកលវិទ្យាល័យ Leeds នោះ កំពុងជឿនលឿនទៅមុខល្អ។ ការដាក់លេខកូដទិន្នន័យ បានចប់សព្វគ្រប់ ហើយការវិភាគទិន្នន័យ និងការចងក្រងរបាយការណ៍កំពុងដំណើរការទៅមុខ។

គម្រោងថ្មីៗបំផុត ៣ ដែលគ្របដណ្ដប់លើបញ្ហាអាហារូបត្ថម្ភ អនាម័យ និងយេនឌ័រ កំពុងស្ថិតក្នុងដំណាក់កាលប្រមូលទិន្នន័យ។ ការសិក្សាទាំងនេះ រួមមាន ការស្រាវជ្រាវពីអ្នកដឹកនាំមតិមហាជនស្ដីពី ការផ្ដល់អាហារឲ្យទារកនិងកុមារតូចៗ (IYCF) ការពិនិត្យផ្ទៀងផ្ទាត់លើលទ្ធផលផ្នែកអនាម័យ ដើម្បីវាយតម្លៃពីផលប៉ះពាល់នៃការកែលំអអនាម័យនៅទីជនបទ និងគន្លងអាជីពសម្រាប់បុគ្គលិកសុខាភិបាលនៅកម្ពុជាផ្អែកលើទស្សនៈយេនឌ័រ។ សម្រាប់ការស្រាវជ្រាវពីពលកម្មកុមារ ដែលជាផ្នែកមួយនៃគម្រោងការលុបបំបាត់ការកេងប្រវ័ញ្ចពលកម្មកុមារ តាមការលើកកម្ពស់ការអប់រំ និងជីវភាពរស់នៅ (EXCEL) ដែលទទួលបានមូលនិធិពីក្រសួងការងារនៃសហរដ្ឋអាមេរិក (USDOL) នោះ ក្រុមស្រាវជ្រាវបានបញ្ចប់ការដាក់លេខកូដទិន្នន័យ និងកំពុងចងក្រងរបាយការណ៍សំយោគចុងក្រោយ។ គម្រោងនេះរំពឹងថានឹងចប់សព្វគ្រប់នៅខែកញ្ញា។

# ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI

## ព្រឹត្តិការណ៍សំខាន់ៗ

បណ្ឌិត ចែម ផល្លា ប្រធានផ្នែកបរិស្ថាន ត្រូវបានតែងតាំងជានាយកស្ដីទី ផ្នែកស្រាវជ្រាវ។ លោកមានបទពិសោធន៍ធំទូលាយ ក្នុងការអនុវត្ត និងគ្រប់គ្រង គម្រោងស្រាវជ្រាវផ្នែកគោលនយោបាយ។

ក្នុងខែមេសា នាយកប្រតិបត្តិនៃវិទ្យាស្ថាន CDRI បានចូលរួមក្នុងកម្មវិធីផ្លាស់ប្ដូរបទពិសោធន៍ របស់ សមាគមប្រជាជនចិនដើម្បីសន្តិភាព និងការកាត់បន្ថយសព្វាវុធ (CPPAD) និងអង្គការមិនមែនរដ្ឋាភិបាលអាស៊ាន (ASEAN NGO) លើប្រធានបទ "សន្តិសុខអាស៊ានសម្រាប់ថ្ងៃអនាគត"។ លោកបានដឹកនាំគណៈប្រតិភូមួយមានអ្នកតំណាង ២០នាក់ មកពី NGOs និងក្រុមគិតគូរវិភាគនានានៃប្រទេស កម្ពុជា ឥណ្ឌូនេស៊ី ម៉ាឡេស៊ី មីយ៉ាន់ម៉ា និង ថៃ ទៅធ្វើទស្សនកិច្ចសិក្សា នៅប្រទេសចិន រយៈពេល ១០ថ្ងៃ នៅឯ ទីក្រុងប៉េកាំង, Ningxia និង Xiamen។ ក្នុងដំណើរទស្សនកិច្ចនេះ លោកនាយកប្រតិបត្តិនៃ CDRI បានជួបពាក់ព័ន្ធការងារជាមួយមន្ត្រីជាន់ខ្ពស់មកពី CPAPD និងបញ្ជាក់ពីការយកចិត្តទុកដាក់ខ្លាំងរបស់ CDRI ក្នុងការបង្កើតកិច្ចសហប្រតិបត្តិការជាមួយនឹងក្រុមគិតគូរវិភាគ និងសហគមន៍សិក្សាស្រាវជ្រាវ និងកសាងគោលនយោបាយរបស់ប្រទេសចិន ដើម្បីផ្លាស់ប្ដូរគំនិតគ្នា និងធនធានមនុស្ស ក្នុងការសិក្សាពីផលពាក់ព័ន្ធផ្នែកគោលនយោបាយនៃយុទ្ធសាស្ត្រការទូតថ្មី របស់ប្រទេសចិន ហៅថា "ខ្សែក្រវ៉ាត់មួយ ផ្លូវមួយ"។ លោកក៏បានអញ្ជើញសមភាគីចិន ឲ្យមកបំពេញទស្សនកិច្ចនៅប្រទេសកម្ពុជាផងដែរ។ ពេលនោះមានឱកាសច្រើនណាស់ដើម្បីកសាងបណ្ដាញជាមួយ សហសេវិកមកពីប្រទេសអាស៊ាននានា។

ការដកឃ្លាជាយុទ្ធសាស្ត្រទៅពិចារណាពីការគ្រប់គ្រង បានធ្វើឡើងនៅខេត្តកំពត នៅថ្ងៃទី ១១-១២ ឧសភា ដើម្បីកសាងផែនការយុទ្ធសាស្ត្រឆ្នាំ២០១៦-២០២០ របស់ CDRI ដែលនឹងផ្ដល់ជាក្របខ័ណ្ឌណែនាំសម្រាប់ កម្មវិធីស្រាវជ្រាវ និងការគាំទ្រផ្នែកប្រតិបត្តិការ ក្នុង ៥ឆ្នាំខាងមុខ។ យុទ្ធសាស្ត្រនេះផ្អែកលើលទ្ធផលសម្រេចបានក្នុងផែនការ ៥ឆ្នាំមុន និងបានដាក់បញ្ចូលលទ្ធផលរកឃើញ និងអនុសាសន៍នៃ ការពិនិត្យបូកសរុបពាក់កណ្ដាលអាណត្តិក្នុងឆ្នាំ២០១៤ ធ្វើឡើងដោយ ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិនៃ ប្រទេសស៊ុយអែត (Sida)។ យុទ្ធសាស្ត្រនេះក៏ស្របគ្នាជាមួយ យុទ្ធសាស្ត្រស្រាវជ្រាវប្រទេសកម្ពុជាឆ្នាំ២០២០ របស់ CDRI ដែរ។ ផែនការយុទ្ធសាស្ត្របង្ហាញជាគោលៗពី បែបបទដែល CDRI នឹងកំណត់នូវអាទិភាពស្រាវជ្រាវផ្នែកគោលនយោបាយ និងរបៀបវារៈអភិវឌ្ឍន៍សមត្ថភាពរបស់ខ្លួន ព្រមទាំងសូចនាករសម្រាប់វាយតម្លៃផលប៉ះពាល់នៃគម្រោងនានា និងយុទ្ធសាស្ត្រស្រាវជ្រាវ។ ផែនការយុទ្ធសាស្ត្រក៏សំដៅដោះស្រាយបញ្ហាជាអាទិភាពក្នុងការរៀបចំអង្គការលេខ ដើម្បីឲ្យ CDRI កាន់តែមានលក្ខណៈធន់ទ្រាំបានល្អទៅនឹងវិបត្តិផ្សេងៗ និងមានចីរភាព។

លោកនាយកប្រតិបត្តិនៃ CDRI បានទទួលការអញ្ជើញពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឲ្យចូលរួមក្នុងវគ្គពិភាក្សាបំផុសគំនិត ពាក់ព័ន្ធនឹង គំនិតផ្ដួចផ្ដើមក្នុងតំបន់របស់ប្រទេសចិន ស្ដីពី គម្រោងអភិវឌ្ឍន៍ Lancang-Mekong។ អ្នកតំណាងមកពីក្រសួងផ្សេងៗ និងវិស័យឯកជនជ្រើសរើសមួយចំនួន បានមកចូលរួមក្នុងកិច្ចប្រជុំនៅថ្ងៃទី ៤ ឧសភា ២០១៥ ហើយមានការចាប់អារម្មណ៍ជាទូទៅថា CDRI ជាស្ថាប័នដ៏សំខាន់មួយអាចចូលរួមចំណែកដល់ ការកសាងគោលនយោបាយអភិវឌ្ឍន៍ក្នុងតំបន់របស់កម្ពុជា។

នៅថ្ងៃទី២៧ ឧសភា លោកនាយកប្រតិបត្តិ អមដោយលោក Larry Strange ទីប្រឹក្សាជាន់ខ្ពស់នៃ CDRI បានចូលជួបសំដែងការគួរសមជាមួយ ឯកឧត្ដម សុខ ចិន្តាសុភា រដ្ឋមន្ត្រីអមនាយករដ្ឋមន្ត្រី និងជា អគ្គលេខាធិការ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) ព្រមទាំងបានពិភាក្សាពីលទ្ធភាពដែល CDRI អាចដើរតួនាទីជួយដល់ CDC ក្នុងការអនុវត្តផែនការអភិវឌ្ឍន៍ឧស្សាហកម្ម។

CDRI បានរួមសហការជាមួយ CPAPD និង ស្ថានទូតចិនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា រៀបចំនូវ កិច្ចសន្ទនាស្ដីពី "កិច្ចសហប្រតិបត្តិការ កម្ពុជា-ចិន៖ ឱកាស និងបញ្ហាប្រឈម"។

តទៅទំព័រ ១៧

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
ទស្សនាវដ្ដី
អភិវឌ្ឍន៍កម្ពុជា
ឆ្នាំទី១៩ លេខ២ ខែមិថុនា ឆ្នាំ២០១៥

ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា បោះពុម្ពផ្សាយដោយ វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នៅភ្នំពេញចំនួន ៤ដង ក្នុងមួយឆ្នាំជាភាសាខ្មែរ និងភាសាអង់គ្លេសនៅពេលដំណាលគ្នា។

ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា ផ្ដល់ជាវេទិកាមួយ ដើម្បីពិភាក្សាពីបញ្ហាអភិវឌ្ឍន៍ដែលកំពុងតែជះឥទ្ធិពលដល់ប្រទេសកម្ពុជា។ អត្ថបទតាមដានសេដ្ឋកិច្ច ផ្ដល់ជូននូវមូលវិចារឯករាជ្យស្ដីពីដំណើរការនៃសេដ្ឋកិច្ចប្រទេសកម្ពុជា។

ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា ស្វាគមន៍អត្ថបទទាំងឡាយពីប្រិយមិត្តអ្នកអាន។ លិខិត ត្រូវចុះហត្ថលេខា អាចផ្ទៀងផ្ទាត់បាន មានលេខទូរស័ព្ទ និងអាសយដ្ឋាន។ អ្នកនិពន្ធ ត្រូវទាក់ទងវិទ្យាស្ថាន CDRI មុននឹងផ្ដល់អត្ថបទ ទោះជាឯកសារនោះមិនទាន់រៀបរយក៏ដោយ។ ឯកសារទាំងអស់នឹងត្រូវកែសម្រួលសម្រាប់ការបោះពុម្ព។ វបសអ សូមរក្សាសិទ្ធិបដិសេធការបោះពុម្ព ដោយមិនចាំបាច់បញ្ជាក់ពីហេតុផល។

វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
អាសយដ្ឋាន ៥៦ ផ្លូវ ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា
ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
(៨៥៥ ២៣) ៨៨១ ៧០១, ៨៨១ ៩១៦, ៨៨៣ ៦០៣ (៨៥៥ ២៣) ៨៨០ ៧៣៤
e-mail: cdri@cdri.org.kh
website: www.cdri.org.kh

9 789995 052065

គ្រឹះស្ថានផ្សាយៈ វបសអ
គ្រប់គ្រងកែសំរួលៈ យូ សិទ្ធិរិទ្ធ
កែសំរួលផលិតកម្មៈ អ៊ុំ ចាន់ថា ខេង សេង និង ម៉េន ច័ន្ទធីតា
សហគ្រាសបោះពុម្ព Invent Cambodia, រូបភាពទំព័រមុខៈ រូបភាព វបសអ

© រក្សាសិទ្ធិ ២០១៥ វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
រក្សាសិទ្ធិគ្រប់យ៉ាង-គ្មានផ្នែកណាមួយនៃការបោះពុម្ពផ្សាយនេះត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងមធ្យោបាយផ្សេងៗដូចជាៈ អេឡិចត្រូនិក យន្តកម្មថតចម្លង... ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពី វិទ្យាស្ថានCDRI ឡើយ។

ISSN 1560-7615 / ISBN 978-99950-52-06-5